## ពង្រាងសំណើគម្រោងទម្រង់ពាក្យសុំក្រុមប្រឹក្សាភិបាល EFSB 2.0 រៀបរៀងដោយបុគ្គលិក

### I. <u>សេចក្តីផ្តើម</u>

នៅខែវិច្ឆិកា ឆ្នាំ 2024 លោកស្រីអភិបាលរដ្ឋ Maura Healey បានចុះហត្ថលេខាប្រកាសឱ្យប្រើ "ច្បាប់លើកកម្ពស់បណ្តាញថាមពលស្អាត ជំរុញសមធម៌ និងការការពារអ្នកបង់ថ្លៃប្រើប្រាស់” [1]("ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024")។ ការផ្តោតសំខាន់នៃច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 គឺការកែទម្រង់ដំណើរការកំណត់ទីតាំងនិងអនុញ្ញាតសម្រាប់ "ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត" (ឬ "CEIF") ដើម្បីជួយសម្រេចបាននូវគោលដៅអាកាសធាតុនិងថាមពលស្អាតរបស់រដ្ឋម៉ាសាឈូសិត។ បទប្បញ្ញត្តិសំខាន់ៗនៃច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 នឹងធ្វើឱ្យប្រសើរឡើងនូវល្បឿននិងប្រសិទ្ធភាពនៃការកំណត់ទីតាំង និងការអនុញ្ញាតឱ្យទីតាំង CEIF នៅថ្នាក់រដ្ឋនិងមូលដ្ឋាន ដោយជាមួយគ្នានោះក៏ធានាឱ្យសហគមន៍ និងភាគីពាក់ព័ន្ធផ្សេងទៀតមានឱកាសល្អ សម្រាប់ការចូលរួមនិង ផ្តល់មតិកែលម្អក្នុងដំណើរការមុនដាក់ពាក្យសុំ និងដំណើរការត្រួតពិនិត្យ។

ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 កំណត់ឡើងវិញនូវតួនាទី និងទំនួលខុសត្រូវរបស់ទីភ្នាក់ងារត្រួតពិនិត្យថ្នាក់រដ្ឋ ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋាន រួមទាំងក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបបនីយភណ្ឌថាមពលថាមពលរបស់រដ្ឋម៉ាសាឈូសិត ("EFSB" ឬ "ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង") ដែលបានអនុវត្តសិទ្ធិអំណាចជាយូរណាស់មកហើយសម្រាប់ការកំណត់ទីតាំងបបនីយភណ្ឌថាមពល និងការអនុញ្ញាតនៅក្នុងរដ្ឋម៉ាសាឈូសិត។[2] ជាពិសេស ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 បង្កើតដំណើរការផ្តល់លិខិតអនុញ្ញាតរួមថ្មី[3] ដែលក្រុមប្រឹក្សាភិបាល EFSB នឹងផ្តល់រាល់ការអនុម័តចាំបាច់ថ្នាក់មូលដ្ឋាន ថ្នាក់តំបន់ និងថ្នាក់រដ្ឋជូនដល់ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតធំ (“LCIEF”) ហើយក្នុងស្ថានភាពមួយចំនួន ផ្តល់លិខិតអនុញ្ញាតរួមថ្នាក់រដ្ឋ និង/លិខិតអនុញ្ញាតរួមថ្នាក់មូលដ្ឋានសម្រាប់ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតតូច”) (“LCEIF”) ។[4] ពង្រាងសំណើគម្រោងនេះគឺផ្តោតទៅលើសេចក្តីណែនាំរបស់ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 ដែលបង្គាប់ឱ្យក្រុមប្រឹក្សា EFSB បង្កើត “ពាក្យសុំស្តង់ដារួម" សម្រាប់ប្រភេទផ្សេងៗនៃទីតាំងហេដ្ឋារចនាសម្ព័ន្ធ

---

1 ច្បាប់លក្ខន្តិកឆ្នាំ 2024 ជំពូក 239។

2 ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបបនីយភណ្ឌថាមពល ដែលជាភ្នាក់ងារពីមុនរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបច្ចុប្បន្ននេះ ត្រូវបានបង្កើតឡើងជាលើកដំបូងនៅក្នុងឆ្នាំ 1973 ។ ច្បាប់លក្ខន្តិកឆ្នាំ 1973 ជំពូក 1232។

3 ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 កំណត់និយមន័យ "លិខិតអនុញ្ញាតរួម” ថាជាលិខិតអនុញ្ញាតដែលចេញដោយក្រុមប្រឹក្សាភិបាលកំណត់ទីតាំង ទៅឱ្យទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតធំមួយ ដែលរួមបញ្ចូលរាល់លិខិតអនុញ្ញាតថ្នាក់ក្រុង ថ្នាក់តំបន់ និងថ្នាក់រដ្ឋទាំងអស់ដែលទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតធំអាចនឹងត្រូវទទួលបានជាលក្ខណៈបុគ្គល លើកលែងតែលិខិតអនុញ្ញាតរបស់សហព័ន្ធជាក់លាក់មួយចំនួនដែលផ្តល់ជូនដោយទីភ្នាក់ងាររដ្ឋជាក់លាក់មួយចំនួន។ អាស្រ័យលើប្រភេទនៃពាក្យស្នើសុំដែលបានដាក់ជូន លិខិតអនុញ្ញាតរួមដែលចេញដោយក្រុមប្រឹក្សាភិបាលកំណត់ទីតាំងទៅឱ្យ SCEIF អាចរួមបញ្ចូលលិខិតអនុញ្ញាតរួមថ្នាក់មូលដ្ឋាន/តំបន់។

4 ច្បាប់ទូទៅ ជំពូក 164 ផ្នែក 69U អនុញ្ញាតឱ្យម្ចាស់សំណើទីតាំង ហេដ្ឋារចនាសម្ព័ន្ធបញ្ជូននិងចែកចាយថាមពលស្អាតខ្នាតតូច (SCT&D) ជ្រើសរើសស្វែងរកលិខិតអនុញ្ញាតរួមពីក្រុមប្រឹក្សាភិបាល EFSB ដែលរួមបញ្ចូលលិខិតអនុញ្ញាតចាំបាច់ថ្នាក់រដ្ឋ ថ្នាក់មូលដ្ឋាន និងថ្នាក់តំបន់ទាំងអស់។ ផ្នែក 69V អនុញ្ញាតឱ្យម្ចាស់សំណើនៃទីតាំងរោងចក្រផលិតថាមពលស្អាតខ្នាតតូច (“SCEG”) និងទីតាំងផ្ទុកថាមពលស្អាតខ្នាតតូច (“SCES”) ជ្រើសរើសស្វែងរកលិខិតអនុញ្ញាតរួមថ្នាក់រដ្ឋពីក្រុមប្រឹក្សាភិបាល EFSB ដែលរួមបញ្ចូលការអនុញ្ញាត ចាំបាច់ថ្នាក់រដ្ឋទាំងអស់។ ផ្នែកទី 69W អនុញ្ញាតឱ្យទីក្រុងជ្រើសរើសបញ្ជូនសំណើសុំលិខិតអនុញ្ញាតរួមថ្នាក់មូលដ្ឋានសម្រាប់ទីតាំង SCEIF ទៅកាន់អភិបាល EFSB សម្រាប់ការវិនិច្ឆ័យ "សាជាថ្មី " ដោយអភិបាល EFSB ត្រូវពិនិត្យលើសំណើសុំលិខិតអនុញ្ញាតរួមថ្នាក់មូលដ្ឋានលើកដំបូងដែលបានដាក់ជូន មន្ត្រីផ្នែកលិខិតអនុញ្ញាតថ្នាក់មូលដ្ឋាន។

CEIF ដែលក្រុមប្រឹក្សាភិបាលកំណត់ទីតាំងនឹងពិនិត្យ និងអនុញ្ញាតក្រោមសិទ្ធិអំណាចដែលបានកែសម្រួលរបស់ខ្លួន។ ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 តម្រូវឱ្យក្រុមប្រឹក្សាភិបាលកំណត់ទីតាំងអភិវឌ្ឍ និងផ្សព្វផ្សាយលិខិតបទដ្ឋាននិងការណែនាំ ដើម្បីអនុវត្តលក្ខខណ្ឌតម្រូវពាក្យសុំត្រឹមថ្ងៃទី 1 ខែមីនា ឆ្នាំ 2026។ ពាក្យសុំស្តង់ដាររួមនេះនឹងបម្រើឱ្យគោលដៅដូចខាងក្រោម៖ ធានាថាក្រុមប្រឹក្សាភិបាល EFSB បំពេញតាមលក្ខខណ្ឌតម្រូវលក្ខន្តិកៈរបស់ខ្លួនក្នុងការបង្កើតពាក្យសុំស្តង់ដាមួយ។ ធានាថាក្រុមប្រឹក្សាភិបាល EFSB មានព័ត៌មានគ្រប់គ្រាន់ដើម្បីធ្វើសេចក្តីសម្រេចពេញលេញរបស់ខ្លួន និងបំពេញតាមកាលកំណត់ច្បាប់របស់ខ្លួនក្នុងការធ្វើសេចក្តីសម្រេចណាមួយ។
ធានាថាក្រុមប្រឹក្សាភិបាល EFSB មានព័ត៌មានគ្រប់គ្រាន់ដើម្បីធ្វើការសន្និដ្ឋានតាមលក្ខន្តិកៈរបស់ខ្លួន (នៅក្នុងផ្នែក 69H) និងផ្តល់តម្លាភាពដល់ភាគីពាក់ព័ន្ធ។

ពង្រាងសំណើគម្រោងរបស់បុគ្គលិកនេះមានវិធីសាស្ត្រជាច្រើនដែលក្រុមប្រឹក្សាភិបាលកំណត់ទីតាំងអាចរៀបចំរចនាសម្ព័ន្ធលក្ខខណ្ឌតម្រូវពាក្យសុំរបស់ខ្លួន។ គោលបំណងនៃពង្រាងសំណើគម្រោងនោះគឺស្នើសុំមតិចូលរួមពីភាគីពាក់ព័ន្ធ មុនពេលក្រុមប្រឹក្សាភិបាលចាប់ផ្តើមដំណើរការអភិវឌ្ឍលិខិតបទដ្ឋានផ្លូវការនៅចុងឆ្នាំនេះ។ ពង្រាងសំណើគម្រោងនេះបង្ហាញពីបរិការណ៍ច្បាប់និងលក្ខន្តិកសម្រាប់ការបង្កើតពាក្យស្នើសុំ ជម្រើសនិងការពិចារណា និងសំណួរសម្រាប់មតិចូលរួមពីភាគីពាក់ព័ន្ធ ដើម្បីជួយជូនដំណឹងដល់ដំណើរការនេះ។

## II. <u>បរិការណ៍សម្រាប់ពង្រាងសំណើគម្រោង</u>

### A. *ការអនុវត្តច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024*

ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 តម្រូវឱ្យក្រុមប្រឹក្សាភិបាល EFSB បង្កើត "ពាក្យសុំស្តង់ដាររួម" មួយដែលត្រូវប្រើប្រាស់នៅពេលដែលអ្នកដាក់ពាក្យសុំ LCEIF ដាក់សំណើទៅក្រុមប្រឹក្សាភិបាលកំណត់ទីតាំង (ច្បាប់ទូទៅ ជំពូក 164 ផ្នែក 69T(b)(ii)) ។ [5,6] នាយកដ្ឋានធនធានថាមពលរដ្ឋម៉ាសាឈូសិត (“DOER”) មានទំនួលខុសត្រូវស្រដៀងគ្នានេះសម្រាប់ការបង្កើត “ពាក្យសុំស្តង់ដាររួម” សម្រាប់ SCEIF ទោះបីជាតួនាទីរបស់នាយកដ្ឋាន DOER មិនរួមបញ្ចូលការវិនិច្ឆ័យលើពាក្យសុំនេះក៏ដោយ។ ច្បាប់ទូទៅ ជំពូក 25A ផ្នែក 21(d)). ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 ក៏ពិពណ៌នាផងដែរអំពីលក្ខណៈវិនិច្ឆ័យពាក្យសុំដូចខាងក្រោមសម្រាប់ពាក្យសុំរបស់ LCEIF និង SCEIF ៖

ពាក្យសុំរបស់ទីតាំង<u>បញ្ជូននិងចែកចាយថាមពលស្អាតខ្នាតធំ</u> (“LCT&D”) ត្រូវរួមបញ្ចូល៖

(i) ការពិពណ៌នាអំពីទីតាំងកន្លែង LCT&D និងតំបន់ជុំវិញ។

(ii) ការវិភាគអំពីលក្ខខណ្ឌតម្រូវសម្រាប់ទីតាំង LCT&D ផ្នែកខាងក្នុងឬខាងក្រៅ ឬទាំងផ្នែកក្នុងនិងខាងក្រៅរដ្ឋម៉ាសាឈូសិត រួមទាំងការពិពណ៌នាអំពីអត្ថប្រយោជន៍ថាមពលផងដែរ។

---

5 ច្បាប់លក្ខន្តិកឆ្នាំ 2024 ជំពូក 239 ផ្នែក 74 នាយកដ្ឋាន DOER ចាំបាច់ត្រូវផ្សព្វផ្សាយលិខិតបទដ្ឋាននានាដើម្បីអនុវត្តការចេញលិខិតអនុញ្ញាតរួមថ្នាក់មូលដ្ឋាន រួមទាំង "ពាក្យសុំស្តង់ដាររួម" សម្រាប់ SCEIF ផងដែរ។ ច្បាប់ទូទៅ ជំពូក 25A ផ្នែក 21(d). ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 មិនបានបញ្ជាក់ច្បាស់អំពីទំនាក់ទំនងរវាងពាក្យសុំនីមួយៗរបស់ក្រុមប្រឹក្សាភិបាល EFSB និងនាយកដ្ឋាន DOER នោះទេ។ ដោយសារតែ SCEIF អាចបញ្ជូនគម្រោងទៅឱ្យក្រុមប្រឹក្សាភិបាល EFSB ដើម្បីពិនិត្យអនុលោមតាមមធ្យោបាយស្នើសុំលិខិតអនុញ្ញាតផ្សេងៗ ដូច្នេះភាពខុសគ្នាណាមួយរវាងពាក្យសុំរបស់ក្រុមប្រឹក្សាភិបាល EFSB និងនាយកដ្ឋាន DOER អាចរារាំងដល់ការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពរបស់ក្រុមប្រឹក្សាភិបាល EFSB ទៅលើគម្រោងរបស់ SCEIF ។ ដូច្នេះ ក្រុមប្រឹក្សាភិបាល EFSB និងនាយកដ្ឋាន DOER នឹងសម្របសម្រួលយ៉ាងជិតស្និទ្ធលើពាក្យសុំនឹងគម្រោងរបស់ SCEIF ។

6 លក្ខខណ្ឌតម្រូវដែលក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបង្កើតពាក្យសុំស្តង់ដាររួមមួយ អនុវត្តចំពោះទីតាំង LCEIF និងមិនអនុវត្តចំពោះទីតាំងចាស់ៗអនុលោមតាមច្បាប់ទូទៅ ជំពូក 164 ផ្នែក 69J និង 69J¼ នោះទេ។

(iii) ការពិពណ៌នាអំពីជម្រើសជំនួសទីតាំង LCT&D រួមទាំងការកំណត់ទីតាំងនិងគម្រោងជំនួសដើម្បីជៀសវាង ឬកាត់បន្ថយ ឬបន្ធូរបន្ថយផលប៉ះពាល់ ប្រសិនបើផលប៉ះពាល់មិនអាចជៀសវាង ឬកាត់បន្ថយបាន។

(iv) ការពិពណ៌នាអំពីផលប៉ះពាល់បរិស្ថាននៃទីតាំងហេដ្ឋារចនាសម្ព័ន្ធ LCT&D រួមទាំងបន្ទុកបរិស្ថាន (ដូចជាការកើនឡើងនៃសំឡេងរំខាន ឬការយកដើមឈើចេញ) និងអត្ថប្រយោជន៍ (ដូចជា "ផ្លូវធ្វើដំណើរកម្សាន្តដែលប្រើប្រាស់រួមគ្នា ឬការចូលទៅកាន់ទីតាំងធម្មជាតិ")។

(v) ភស្តុតាងបញ្ជាក់ថា អ្នកដាក់ពាក្យសុំបានបំពេញតាមលក្ខខណ្ឌតម្រូវការពិគ្រោះយោបល់មុនដាក់ពាក្យសុំ និងលក្ខខណ្ឌតម្រូវការចូលរួមសហគមន៍ទាំងអស់ដែលបង្កើតឡើងដោយក្រុមប្រឹក្សាភិបាលកំណត់ទីតាំង ហើយបើមិនដូច្នេះទេ ត្រូវមានការបង្ហាញអំពីហេតុផលសមស្របសម្រាប់ការលះបង់ចោលលក្ខខណ្ឌតម្រូវដែលអ្នកដាក់ពាក្យសុំមិនអាចបំពេញបាន។ និង

(vi) ការវិភាគលើផលប៉ះពាល់ជារួម

**ច្បាប់លក្ខន្តិកឆ្នាំ 2024 ជំពូក 239 ផ្នែក 74**

ពាក្យសុំរបស់ទីតាំងរោងចក្រ <u>ផលិតថាមពលស្អាតខ្នាតធំ</u> (“LCEG”) ឬពាក្យសុំរបស់ទីតាំង<u>ប្រព័ន្ធស្តុកថាមពលស្អាតធំ</u> (“LCES”) តម្រូវឱ្យមានដើម្បីរួមបញ្ចូលរាល់លក្ខខណ្ឌតម្រូវខាងលើទាំងអស់សម្រាប់ LCT&D *លើកលែងតែ* ចំណុចផ្នែក **69**T(c)(ii) (មិនមានបង្ហាញពី “តម្រូវការ" ចាំបាច់); និងសម្រាប់ចំណុច ផ្នែក **69**T(c)(iii) , (មិនមានលក្ខខណ្ឌតម្រូវសម្រាប់ការពិពណ៌នាអំពីជម្រើសគម្រោងជំនួស)។[7] ច្បាប់ទូទៅ ជំពូក **164** ផ្នែក **69**T(ii), (iii). ទោះបីជាទីតាំង LCEG មិនតម្រូវឱ្យបង្ហាញពីតម្រូវការគម្រោងក៏ដោយ ក៏ពាក្យសុំរបស់ទីតាំង LCEG និង LCES ត្រូវបានតម្រូវឱ្យរួមបញ្ចូល "ការពិពណ៌នាអំពីអត្ថប្រយោជន៍ថាមពល" នៃគម្រោងនោះដែរ។ ច្បាប់ទូទៅ ជំពូក **164** ផ្នែក **69**T (d)(i).

<u>ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតតូច</u> ប្រសិនបើម្ចាស់សំណើទីតាំង SCEIF ជ្រើសរើសស្វែងលិខិតអនុញ្ញាតរួមថ្នាក់រដ្ឋ និង/ឬ លិខិតអនុញ្ញាតរួមថ្នាក់មូលដ្ឋានពីក្រុមប្រឹក្សាកំណត់ទីតាំងនោះ ក្រុមប្រឹក្សាកំណត់ទីតាំងនឹងតម្រូវឱ្យពួកគេបំពេញពាក្យសុំស្តង់ដាររួមមួយ។ <u>មើល</u>ច្បាប់លក្ខន្តិកឆ្នាំ **2024** ជំពូក **239** ផ្នែក **74** នៅក្នុងករណីទាំងនេះ ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ **2024** ណែនាំឱ្យក្រុមប្រឹក្សាភិបាលកំណត់ទីតាំងប្រើប្រាស់ពាក្យសុំដូចគ្នាតែមួយ ដូចបានកំណត់សម្រាប់ទម្រង់បែប បទត្រូវគ្នារបស់ទីតាំង LCEIF។ លើសពីនេះ ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ **2024** អនុញ្ញាតឱ្យទីក្រុងបញ្ជូនពាក្យសុំលិខិតអនុញ្ញាតរួមថ្នាក់មូលដ្ឋានទៅកាន់ក្រុមប្រឹក្សាភិបាល EFSB សម្រាប់ ការវិនិច្ឆ័យសាជាថ្មីពីក្រុមប្រឹក្សាភិបាល EFSB ដែលនឹងផ្អែកលើពាក្យសុំលិខិតអនុញ្ញាតរួមថ្នាក់ មូលដ្ឋានដូចគ្នាដែលបានដាក់ជូនរដ្ឋាភិបាលមូលដ្ឋាន។ ច្បាប់ទូទៅ ជំពូក **164** ផ្នែក **69**W(a).

<u>ការលើកលែងការកំណត់តំបន់៖</u> ផ្នែក **37** និង **91** នៃច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ **2024** ការផ្ទេរសិទ្ធិអំណាចលើកលែងការកំណត់តំបន់របស់នាយកដ្ឋានសេវាសាធារណៈ (“DPU”) ទៅកាន់ក្រុមប្រឹក្សាភិបាល។ ច្បាប់ទូទៅ ជំពូក **40**A ផ្នែក **3** និងច្បាប់លក្ខន្តិកឆ្នាំ **1956** ជំពូក **665** ផ្នែក **6** (សម្រាប់ការកំណត់តំបន់ទីក្រុង Boston)។ ការផ្ទេរសិទ្ធិអំណាចលើកលែងការកំណត់តំបន់ជំពូកទី **40**A បានកើតឡើងនៅថ្ងៃទី **18** ខែកុម្ភៈ ឆ្នាំ **2025**, ការផ្ទេរសិទ្ធិអំណាចលើកលែងការកំណត់ទីតាំងតំបន់នៅទីក្រុង Boston នៅថ្ងៃទី **1** ខែមីនា ឆ្នាំ **2026**។ ច្បាប់លក្ខន្តិកឆ្នាំ **2024** ជំពូក **239** ផ្នែក **37**, **91**, **139** សិទ្ធិអំណាចលើកលែងការកំណត់តំបន់នេះអាចអនុវត្តបានចំពោះគម្រោងថាមពលដែលបំពេញតាមលក្ខណៈវិនិច្ឆ័យដែលបានបង្កើតឡើង ហើយអាចត្រូវបានស្វែងរកដោយខ្លួនឯង ឬដោយភ្ជាប់ជាមួយសិទ្ធិអំណាចលិខិតអនុញ្ញាតរបស់ក្រុមប្រឹក្សាភិបាល EFSB ផ្សេងទៀត។ ជាទូទៅ វិសាលភាពនៃការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងសម្រាប់ការលើកលែងការកំណត់តំបន់គឺមានលក្ខណៈទូលំទូលាយ ហើយស្រដៀងគ្នាទៅនឹងការអនុម័តរបស់ខ្លួនក្នុងការសាងសង់។ សំណើសុំ

---

[7] ពាក្យសុំរបស់ទីតាំង LCEG/LCES តម្រូវឱ្យមានការពិពណ៌នាអំពីដំណើរការជ្រើសរើសទីតាំងគម្រោង និងការវិភាគជម្រើស ជំនួសដែលប្រើប្រាស់ក្នុងការជ្រើសរើសទីតាំងគម្រោងដែលបានស្នើឡើង ដើម្បីជៀសវាង កាត់បន្ថយ និងបន្ធូរបន្ថយផលប៉ះពាល់។ ច្បាប់ទូទៅ ជំពូក **164** ផ្នែក **69**T (d)(iii).

លើកលែងការកំណត់តំបន់ក៏អាចនឹងចាំបាច់ត្រូវមានក្នុងពេលដំណាលគ្នានឹងការអនុញ្ញាតរួម ដែលអាចតម្រូវឱ្យម្ចាស់សំណើដាក់ជូនព័ត៌មានបន្ថែមរួមជាមួយនឹងពាក្យសុំ។

B. *លក្ខណៈសំខាន់ៗផ្សេងទៀតនៃពាក្យសុំ*

ពាក្យសុំចាំបាច់ត្រូវកំណត់ឱ្យបានច្បាស់លាស់នូវព័ត៌មានដែលត្រូវការដើម្បីឱ្យអ្នកដាក់ពាក្យ សុំដឹងពីអ្វីដែលរំពឹងថានឹងទទួលបាននូវការសម្រេចពេញលេញ។ ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 តម្រូវឱ្យក្រុមប្រឹក្សាភិបាលកំណត់ទីតាំងសម្រេចថាតើពាក្យសុំរបស់ទីតាំង CEIF ត្រូវតែមានលក្ខណៈពេញលេញក្នុងរយៈពេល 30 ថ្ងៃបន្ទាប់ពីការទទួលពាក្យសុំ។ ប្រសិនបើចាត់ទុកថាពាក្យសុំមិនពេញលេញ អ្នកដាក់ពាក្យសុំមានពេល 30 ថ្ងៃដើម្បីដោះស្រាយបញ្ហាខ្វះចន្លោះណាមួយដែលកំណត់ដោយក្រុមប្រឹក្សាភិបាល មុនពេលពាក្យសុំនោះត្រូវបានបដិសេធ។ ក្រុមប្រឹក្សាភិបាលអាចផ្តល់ការពន្យារពេលដើម្បីដោះស្រាយបញ្ហាខ្វះចន្លោះ ប្រសិនបើអ្នកដាក់ពាក្យសុំអាចបង្ហាញពីស្ថាន ភាពដែលសមនឹងទទួលបានការអនុគ្រោះ (ច្បាប់ LCEIF ផ្នែក 69T(f), ច្បាប់ SCT&D ផ្នែក 69U(b), ច្បាប់ SCEG & SCES ផ្នែក 69V(b))។ ក្របខណ្ឌពេលវេលាកំណត់ដែលបានបញ្ជាក់នៅក្នុងច្បាប់ បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 សម្រាប់សេចក្តីសម្រេចស្ថាពររបស់ក្រុមប្រឹក្សាភិបាល ចាប់ផ្តើមនៅពេលដែលពាក្យសុំត្រូវបានកំណត់ថាពេញលេញ។

ដើម្បីពន្លឿនការកំណត់ទីតាំងនិងការអនុញ្ញាត គោលដៅសំខាន់មួយនៃច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 នោះនឹងមិនសម្រេចបានឡើយ ប្រសិនបើម្ចាស់សំណើមិនប្រាកដប្រជាអំពីអ្វីដែលរំពឹងទុកនៅក្នុងពាក្យសុំ ហើយសកម្មភាពកែតម្រូវគឺចាំបាច់ត្រូវមានដើម្បីទទួលបានការសម្រេចចិត្តពេញលេញ (សូមមើលផ្នែក III(F) ខាងក្រោម)។ ការពិពណ៌នារបស់ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 អំពី "ពាក្យសុំស្តង់ដាររួម" ហាក់ដូចជាបង្ហាញពីការបង្កើតពាក្យសុំដែលមានលក្ខណៈជាទម្រង់បែបបទ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារភាពស្មុគស្មាញ និងកត្តាជាក់លាក់ដែលជារឿយៗពាក់ព័ន្ធនឹងការកំណត់ទីតាំងនិងអនុញ្ញាតសម្រាប់ទីតាំងរោងចក្រថាមពល ដូច្នេះការប្រើប្រាស់ពាក្យសុំមានលក្ខណៈជាទម្រង់បែបបទតឹងរឹងគឺមិនមែនជារឿងទូទៅនោះទេក្នុងចំណោមអង្គភាពកំណត់ទីតាំងនៅក្នុងរដ្ឋផ្សេងទៀតដែលបុគ្គលិកក្រុមប្រឹក្សាភិបាល EFSB បានធ្វើការស្ទង់មតិ។ ផ្ទុយទៅវិញ រដ្ឋផ្សេងទៀតដែលមានមុខងារ "ផ្តល់លិខិតអនុញ្ញាតរួម" ប្រហាក់ប្រហែលនេះ អាចនឹងប្រើទម្រង់ឯកសារទូទៅបន្ថែមទៀត ដែលជាធម្មតារួមបញ្ចូលធាតុផ្សំដូចខាងក្រោម៖

- ប្រធានបទដែលបានកំណត់ នាមវលីស្តង់ដា លំដាប់រចនាសម្ព័ន្ធនៃប្រធានបទដែលចាំបាច់ និងឯកសារគាំទ្រ និងសេចក្តីណែនាំអំពីការដាក់ឯកសារលម្អិត។
- ស្តង់ដានិងលក្ខខណ្ឌតម្រូវការដែលអាចអនុវត្តបាន បញ្ជាក់ដោយបច្ចេកវិទ្យា/ទំហំរបស់ទីតាំងគ្រឹះស្ថាន។
- ទិដ្ឋភាពទូទៅនៃគម្រោងចាំបាច់ សេចក្តីសង្ខេប និងសេចក្តីអធិប្បាយដែលពន្យល់អំពីខ្លឹមសារនៃពាក្យសុំជាភាសាសាមញ្ញដែលអាចយល់បានដោយងាយពីសំណាក់សាធារណជនទូទៅ និងភាគីពាក់ព័ន្ធផ្សេងទៀតដែលមិនធ្លាប់ដឹងអំពីខ្លឹមសារពាក្យសុំនេះ។ និង
- ឯកសារគាំទ្រចាំបាច់។

C. *កិច្ចសហប្រតិបត្តិការជាមួយភ្នាក់ងារអនុញ្ញាតថ្នាក់រដ្ឋនិងថ្នាក់មូលដ្ឋានទៅលើពាក្យសុំរបស់ក្រុមប្រឹក្សាភិបាល* EFSB

សមាជិកភាពរបស់ក្រុមប្រឹក្សាកំណត់ទីតាំងធានា ទស្សនៈចម្រុះនានាត្រូវបានពិចារណានៅក្នុងការពិភាក្សាលម្អិត និងសេចក្តីសម្រេចចិត្តរបស់ខ្លួន។ សមាជិកភាពរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងក្រោមក្រុមប្រឹក្សាភិបាល "EFSB 1.0" (ក្រុមប្រឹក្សាកំណត់ទីតាំងមុនពេលការកែប្រែនៅក្នុងច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024) រួមមានសមាជិកមកពីទីភ្នាក់ងាររដ្ឋចំនួនប្រាំ បូករួមទាំងសមាជិកសាធារណៈចំនួនបីរូប។ សមាជិកភាពរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងនៅក្រោមក្រុមប្រឹក្សាភិបាល "EFSB 2.0" (ក្រុមប្រឹក្សាកំណត់ទីតាំងដែលបានកែប្រែចេញមកពីច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024) រួមមានតំណាងមកពីទីភ្នាក់ងាររដ្ឋចំនួនប្រាំពីរ បូករួមទាំងសមាជិកសាធារណៈចំនួនបួនរូប។ ច្បាប់ទូទៅ ជំពូក 164 ផ្នែក 69H សមាជិកសាធារណៈថ្មីពីររូបដែលត្រូវបានដាក់បន្ថែមទៅក្នុងក្រុមប្រឹក្សាភិបាលកំណត់ទីតាំងនៅក្នុងក្រុមប្រឹក្សា EFSB 2.0 ដែលជាតំណាងនៃសមាគម

ទីក្រុងរដ្ឋម៉ាសាឈូសិត ("MMA") និងសមាគមទីភ្នាក់ងារផែនការតំបន់រដ្ឋម៉ាសាឈូសិត ("MARPA") នាំយកចំណេះជំនាញនិងទស្សនវិស័យលើការផ្តល់លិខិតអនុញ្ញាតថ្នាក់ក្រុងនិងថ្នាក់តំបន់ ជូនដល់ក្រុមប្រឹក្សាភិបាល។[8]

បន្ថែមពីលើទស្សនវិស័យចម្រុះដែលឆ្លុះបញ្ចាំងនៅក្នុងសមាជិកភាពភ្នាក់ងារចម្រុះរបស់ក្រុមប្រឹក្សាភិបាល និងសមាជិកសាធារណៈរបស់ខ្លួន បុគ្គលិកក្រុមប្រឹក្សាភិបាលធ្វើការសហការជាមួយភ្នាក់ងារជាច្រើនទៀត។ ឧទាហរណ៍ បុគ្គលិកក្រុមប្រឹក្សាភិបាលកំណត់ទីតាំង និងនាយកដ្ឋាន DPU មានទំនាក់ទំនងយ៉ាងជិតស្និទ្ធចាប់តាំងពីបុគ្គលិកក្រុមប្រឹក្សាភិបាលត្រូវបានផ្លាស់ប្តូរទីតាំងរដ្ឋបាលទៅកាន់នាយកដ្ឋាន DPU ក្នុងឆ្នាំ 1992 ហើយត្រូវបានបង្កើតទៅជា "ផ្នែកកំណត់ទីតាំងរបស់នាយកដ្ឋាន DPU"។ បុគ្គលិកក្រុមប្រឹក្សាភិបាលកំណត់ទីតាំង ក៏ធ្វើការដោយសហការយ៉ាងជិតស្និទ្ធជាមួយការិយាល័យច្បាប់គោលនយោបាយបរិស្ថានរដ្ឋម៉ាសាឈូសិត ("MEPA") ដែលទាក់ទងនឹងប្រធានបទបរិស្ថានស្រដៀងគ្នា និងគម្រោងថាមពលដូចគ្នានេះជាច្រើនទៀត។[9] បុគ្គលិកក្រុមប្រឹក្សាភិបាលកំណត់ទីតាំងក៏សហការនិងពិគ្រោះយោបល់ជាមួយភ្នាក់ងាររដ្ឋនិងមូលដ្ឋានជាច្រើនទៀតផងដែរ តាមការចាំបាច់។

ក្នុងការបង្កើតលិខិតបទដ្ឋានសម្រាប់ក្រុមប្រឹក្សាភិបាល EFSB 2.0 ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 តម្រូវជាពិសេសឱ្យក្រុមប្រឹក្សាភិបាលកំណត់ទីតាំងពិគ្រោះយោបល់ជាមួយៈ នាយកដ្ឋាន DPU ការិយាល័យ MEPA នាយកដ្ឋាន DOER នាយកដ្ឋានការពារបរិស្ថានរដ្ឋម៉ាសាឈូសិត ("MassDEP") នាយកដ្ឋាននេសាទនិងល្បែងកម្សាន្ត (DFG) និង នាយកដ្ឋានអភិរក្សនិងការកម្សាន្ត នាយកដ្ឋានធនធានកសិកម្មរដ្ឋម៉ាសាឈូសិត ("MDAR") នាយកដ្ឋានដឹកជញ្ជូនរដ្ឋម៉ាសាឈូសិត ("MassDOT") ការិយាល័យប្រតិបត្តិសុវត្ថិភាពនិងសន្តិសុខសាធារណៈ ("EOPSS") និងភ្នាក់ងារ អាជ្ញាធរ និងនាយកដ្ឋានផ្សេងទៀតទាំងអស់ដែលការអនុម័ត សេចក្តីបង្គាប់កំណត់ លក្ខខណ្ឌ លិខិតអនុញ្ញាត អាជ្ញាប័ណ្ណ វិញ្ញាបនបត្រ ឬការអនុញ្ញាតជាទម្រង់ណាមួយគឺត្រូវបានទាមទារមុនពេល ឬសម្រាប់ការសាងសង់ SCEIF ឬ LCEIF ឬប្រភេទកន្លែងផ្សេងទៀតដែលមានយុត្តាធិការរបស់ក្រុមប្រឹក្សាភិបាល EFSB ។ ច្បាប់លក្ខន្តិកឆ្នាំ 2024 ជំពូក 239 ផ្នែក 132

D. *ទិដ្ឋភាពទូទៅនៃការអនុវត្តពាក្យសុំក្រុមប្រឹក្សាកំណត់ទីតាំងដែលមានស្រាប់*

លក្ខខណ្ឌតម្រូវការដាក់ពាក្យសុំទូទៅសម្រាប់ញត្តិស្នើសុំរបស់ទីតាំងថាមពលក្នុងដែនយុត្តាធិការបច្ចុប្បន្ននៅក្នុងការសាងសង់ ត្រូវបានកំណត់នៅក្នុងច្បាប់ទូទៅ ជំពូក 164 ផ្នែក 69J និង 69J¼។ [10] ម្ចាស់សំណើគម្រោងដែលស្វែងរកការយល់ព្រមពីក្រុមប្រឹក្សាភិបាលកំណត់ទីតាំងសម្រាប់

---

[8] ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 ក៏បង្កើតសមាជិកសាធារណៈថ្មីមួយទៀតនៃក្រុមប្រឹក្សាភិបាលកំណត់ទីតាំង "មានបទពិសោធន៍ក្នុងបញ្ហាយុត្តិធម៌បរិស្ថាន ឬអធិបតេយ្យភាពជនជាតិដើមភាគតិច"។ ច្បាប់ទូទៅ ជំពូក 164 ផ្នែក 69H

[9] ច្បាប់លក្ខន្តិកឆ្នាំ 2024 ជំពូក 239 ផ្នែក 62 ចែងថា ទាំងក្រុមប្រឹក្សាកំណត់ទីតាំង ឬម្ចាស់សំណើគម្រោង គឺសុទ្ធតែស្ថិតនៅក្រោមលក្ខខណ្ឌតម្រូវរបស់ការិយាល័យ MEPA (អនុលោមតាមច្បាប់ទូទៅ ជំពូក 30 ផ្នែក 61 ដល់ 62L) សម្រាប់គម្រោងទីតាំង CEIF ។ ទោះយ៉ាងណា ច្បាប់លក្ខន្តិកឆ្នាំ 2024 ជំពូក 239 ផ្នែក 74 ចែងបញ្ជាក់អំពីតួនាទីសម្រាប់ការិយាល័យ MEPA ក្នុងការពិគ្រោះយោបល់មុនដាក់ពាក្យសុំដែលអនុវត្តចំពោះអ្នកដាក់ពាក្យសុំរបស់ទីតាំង LCEIF និង SCEIF ។ ច្បាប់ទូទៅ ជំពូក 164, ផ្នែក 69T(b), 69U(b), 69V(b).

[10] ញត្តិស្នើសុំសាងសង់ទីតាំងមួយត្រូវរួមបញ្ចូលនូវព័ត៌មានដូចខាងក្រោមជាទម្រង់និងសេចក្តីលម្អិតដែលក្រុមប្រឹក្សាភិបាលបានកំណត់ទៅតាមដំណាក់កាលៈ (1) ការពិពណ៌នាអំពី ទីកន្លែងទីតាំង និងតំបន់ជុំវិញ (2) ការវិភាគអំពីលក្ខខណ្ឌតម្រូវសម្រាប់ទីតាំងនៅខាងក្នុងឬខាងក្រៅ ឬទាំងខាងក្នុងនិងខាងក្រៅរដ្ឋម៉ាសាឈូសិត (3) ការពិពណ៌នាអំពីជម្រើសជំនួសទីតាំងនោះ ដូចជាវិធីសាស្ត្រផ្សេងទៀតនៃការបញ្ជូនឬរក្សាទុកថាមពល កន្លែងទីតាំងផ្សេងទៀត ប្រភពថាមពលអគ្គិសនីឬឧស្ម័ន ឬការកាត់បន្ថយលក្ខខណ្ឌតម្រូវតាមរយៈការគ្រប់គ្រងបន្ទុក និង (4) ការពិពណ៌នាអំពីផលប៉ះពាល់បរិស្ថាននៃទីតាំងគ្រឹះស្ថាន។ ច្បាប់ទូទៅ ជំពូក 164 ផ្នែក 69J. ច្បាប់ទូទៅ ជំពូក 164 ផ្នែក 69J¼.

ទីតាំងក្នុងដែនយុត្តាធិការ បានរៀបចំនិងបញ្ជូនសម្ភារៈឯកសារជាច្រើនប្រភេទទៅឱ្យក្រុមប្រឹក្សាកំណត់ទីតាំងនៅក្នុងការដាក់ឯកសារលើកដំបូងរបស់ពួកគេ ដែលភាគច្រើនពឹងផ្អែកលើករណីពីមុនៗនៅក្នុងការដោះស្រាយប្រភេទប្រធានបទជាច្រើនដែលបានកំណត់ដោយច្បាប់លក្ខន្តិក។ ការដាក់ឯកសារដំបូងរួមមាន "ញត្តិស្នើសុំ" ដែលចែងនូវសេចក្តីសង្ខេបនៃគម្រោងដែលបានស្នើឡើង បទប្បញ្ញត្តិច្បាប់និងលិខិតបទដ្ឋានដែលអាចអនុវត្តបានចំពោះការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាកំណត់ ទីតាំងទៅលើគម្រោងដែលបានស្នើឡើង ទិដ្ឋភាពទូទៅនៃភស្តុតាងសំខាន់ៗដែលផ្តល់ជូនក្នុងការគាំទ្រគម្រោងដែលបានស្នើឡើង និងមូលដ្ឋាននៃអនុសាសន៍របស់អ្នកស្នើសុំសម្រាប់ការអនុម័តរបស់ក្រុមប្រឹក្សាភិបាលកំណត់ទៅតាំងទៅលើគម្រោងដែលបានស្នើឡើង។

ការបំពេញបន្ថែមលើញត្តិស្នើសុំគឺជាការចងក្រងព័ត៌មាននិងការវិភាគមួយ ឬច្រើន (ហៅថា "ការវិភាគគម្រោង") ដែលផ្តល់ទាំងទិដ្ឋភាពទូទៅជារួម និងទិន្នន័យនិងព័ត៌មានលម្អិតដែលតម្រូវចាំបាច់តាមច្បាប់ក្នុងការពិនិត្យឡើងវិញរបស់ក្រុមប្រឹក្សាកំណត់ទីតាំង និងប្រធានបទផ្សេងទៀតដែលកើតមានតាមពេលវេលា ដែលជាបញ្ហាករណីធ្លាប់មានពីមុន។[11] ឯកសារបន្ថែមដែលរួមបញ្ចូលជាមួយការវិភាគ គម្រោង អាចផ្តល់នូវទិន្នន័យគាំទ្រដូចជាផែនទីលម្អិត ការសិក្សាបច្ចេកទេសនិងវិទ្យាសាស្ត្រលើប្រធានបទផ្សេងៗ ការបង្ហាញគម្រោងនិងព័ត៌មានផលប៉ះពាល់ជារូបភាពផ្សេងៗ, ទិន្នន័យ ហិរញ្ញវត្ថុ, សេចក្តីសង្ខេបការប្រជុំរបស់ភាគីពាក់ព័ន្ធនិងភ្នាក់ងារអនុញ្ញាត, បទប្បញ្ញត្តិកំណត់តំបន់, និងសម្ភារៈឯកសារផ្សេងទៀតដែលអ្នកស្នើសុំអាចផ្តល់ជូនដើម្បីផ្តល់ដំណឹងអំពីដំណើរការពិនិត្យ។

ក្រោមសិទ្ធិអំណាចជាយូរមកហើយរបស់ខ្លួនក្នុងការចេញវិញ្ញាបនបត្របញ្ជាក់ផលប៉ះពាល់បរិស្ថាននិងផលប្រយោជន៍សាធារណៈ (ហៅថា "វិញ្ញាបនបត្រ") ក្រុមប្រឹក្សាភិបាលត្រូវបានអនុញ្ញាតឱ្យចេញសមាសភាពរួមនៃលិខិតអនុញ្ញាតនិងការយល់ព្រមថ្នាក់រដ្ឋនិងមូលដ្ឋានទាំងអស់ដែលតម្រូវឱ្យមានដើម្បីសាងសង់ និងដំណើរការគម្រោង ដែលសមាសភាគរួមនោះមានមុខងារស្មើនឹងលិខិតអនុញ្ញាតរួមដែលទើបបង្កើតថ្មី។[12] ទោះជាយ៉ាងណាក៏ដោយ មិនដូចជាលិខិតអនុញ្ញាតដែលបានបង្កើតថ្មីនៅក្នុងក្រុមប្រឹក្សាភិបាល EFSB **2.0** នោះទេ ការចេញវិញ្ញាបនបត្រមួយគឺតម្រូវឱ្យមានសេចក្តីសម្រេចស្ថាពររបស់ក្រុមប្រឹក្សាភិបាលដែលផ្តល់ "ការយល់ព្រមក្នុងការសាងសង់"។ លិខិតបទដ្ឋានរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង តម្រូវឱ្យពាក្យសុំរួមបញ្ចូលចំណុចមួយចំនួនដូចខាងក្រោម៖ **(1)** ការព្យាករណ៍រយៈពេលវែងដែលចងក្រងឯកសារតម្រូវការសម្រាប់ទីតាំងគ្រឹះស្ថាន **(2)** ផែនទីផ្សេងៗ **(3)** ផែនការទីតាំងគ្រឹះស្ថាន **(4)** រូបថតទីតាំងនិងការបង្ហាញទីតាំងគ្រឹះស្ថាន **(5)** បញ្ជីពេញលេញនៃអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងការអនុម័តតាមច្បាប់ផ្សេងទៀត ទាំងអស់ដែលត្រូវការចាំបាច់ និងដែលបានទទួល **(6)** ព័ត៌មានផ្សេងទៀតដែលអ្នកដាក់ពាក្យសុំចាត់ទុកថាពាក់ព័ន្ធ។ ជំពូក **980** នៃក្រមបញ្ញត្តិរដ្ឋម៉ាសាជូសិត (CMR) លេខ **6.03(3)**.[13]

---

[11] ប្រធានបទនៃការវិភាគគម្រោងជាធម្មតារួមមាន៖ **(1)** ទិដ្ឋភាពទូទៅនៃគម្រោង **(2)** តម្រូវការគម្រោង **(3)** គម្រោងជំនួស **(4)** ការជ្រើសរើសផ្លូវ/ទីតាំង **(5)** វិធីសាស្ត្រសាងសង់ **(6)** ផលប៉ះពាល់នៃគម្រោង **(7)** ថ្លៃចំណាយ **(8)** ការវិភាគលើបរិស្ថាន និងភាពអាចទុកចិត្តបាននៃផ្លូវ/ទីតាំងដែលបានស្នើឡើង និងផ្លូវ/ទីតាំងជំនួស និង **(9)** ភាពស៊ីសង្វាក់គ្នាជាមួយនឹងគោលនយោបាយថាមពល និងបរិស្ថានរបស់រដ្ឋម៉ាសាឈូសិត។

[12] ក្រុមប្រឹក្សាកំណត់ទីតាំងរក្សាសិទ្ធិចេញវិញ្ញាបនបត្ររបស់ខ្លួនសម្រាប់គម្រោងដែល <u>មិនមែនជា</u>ទីតាំង CEIF (**ឧ.** ទីកន្លែងបំពង់បង្ហូរនិងស្តុកឧស្ម័ន ទីកន្លែងបង្កើតឥន្ធនៈហ្វូស៊ីល ។ល។) ក្រោមច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ **2024** ។ សម្រាប់ទីតាំង CEIF លិខិតអនុញ្ញាតរួមនៃច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ **2024** មានប្រសិទ្ធភាពអនុវត្តជំនួសវិញ្ញាបនបត្ររបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង ដែលជាមធ្យោបាយមួយនៃការផ្តល់លិខិតអនុញ្ញាតរួមចាំបាច់ថ្នាក់រដ្ឋ ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋានទាំងអស់សម្រាប់ទីតាំង CEIF ។

[13] សមាសធាតុពាក្យសុំវិញ្ញាបនបត្រមួយចំនួនដែលបានបញ្ជាក់នៅក្នុងក្រម CMR ជំពូក **980** ផ្នែក **6.03(3)** (ដូចជាការព្យាករណ៍រយៈពេលវែងជាដើម) លែងត្រូវបានប្រើប្រាស់ដោយក្រុមប្រឹក្សាភិបាល EFSB ទៀតហើយ ដូច្នេះហើយ អ្នកដាក់ពាក្យសុំមិនចាំបាច់ត្រូវមាននោះទេ។

ការអនុវត្តលក្ខខណ្ឌតម្រូវនៃច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 សម្រាប់ការបង្កើត "ពាក្យសុំស្តង់ដាររួម" សម្រាប់ឯកសារតម្កល់របស់ក្រុមប្រឹក្សាភិបាល EFSB នាពេលអនាគត គួរតែជួយដោះស្រាយបញ្ហាខ្វះចន្លោះនៃវិធីសាស្ត្ររបស់ក្រុមប្រឹក្សាភិបាល EFSB បច្ចុប្បន្នដូចខាងក្រោម៖

- ឯកសារតម្កល់មិនមែនសុទ្ធតែងអនុវត្តតាមរចនាសម្ព័ន្ធនិងអង្គការលេខដូចគ្នាទេ ដែលធ្វើឱ្យមានការពិបាក មិនអាចឱ្យក្រុមប្រឹក្សាភិបាលកំណត់ទីតាំងនិងភាគីផ្សេងទៀតមើលឃើញពីអត្ថប្រយោជន៍នៃសម្ភារៈឯកសារនោះបានដោយងាយឡើយ។ អវត្តមាននៃទម្រង់ស្តង់ដាណាមួយអាចធ្វើឱ្យមានការពិបាកក្នុងការស្វែងរកព័ត៌មានលម្អិតពិពណ៌នាជាមូលដ្ឋានអំពីគម្រោង។

- ឯកសារតម្កល់មិនបន្តផ្តល់នូវឯកសារគាំទ្រគ្រប់គ្រាន់ ដែលជារឿយៗនាំឱ្យមានការសាកសួរជាប្រចាំពីក្រុមប្រឹក្សាភិបាលកំណត់ទីតាំងសម្រាប់ព័ត៌មានដែលអាចនឹងពន្យារពេលដំណើរការ។

- វិធីសាស្ត្រដែលប្រើដោយអ្នកដាក់ញត្តិស្នើសុំដើម្បីវិភាគផលប៉ះពាល់ផ្សេងៗ ខ្វះប្រភពទិន្នន័យស្របគ្នា វិធីសាស្ត្រគណនា គំរូ និងការសន្មត់។

- ការរំពឹងទុកព័ត៌មានរបស់ក្រុមប្រឹក្សាកំណត់ទីតាំងផ្អែកលើគំរូពីមុនមក ដែលមិនបានចែងបញ្ជាក់ច្បាស់លាស់នៅក្នុងលិខិតបទដ្ឋានឬការណែនាំនោះទេ ប្រហែលជាមិនត្រូវបានអ្នកដាក់ពាក្យសុំគោរពតាមឡើយ។ និង

- ភាពខ្វះចន្លោះនៃព័ត៌មានដែលអាចជៀសវាងបានតាមរយៈវិធីសាស្ត្រជាប្រព័ន្ធបន្ថែមទៀតអាចពន្យារពេលដំណើរការដោយសារមានការសាកសួរបន្ថែមពីក្រុមប្រឹក្សាភិបាលកំណត់ទីតាំង។

## III. <u>ពាង្រាងសំណើគម្រោងតាមរយៈពាក្យសុំ</u>

### A. <u>*ប្រភេទពាក្យសុំ៖ គំរូរួមធៀបនឹងគំរូដែលបង្កើតឡើងក្នុងគោលបំណងជាក់លាក់*</u>

ពាក្យសុំសម្រាប់ក្រុមប្រឹក្សាភិបាល EFSB **2.0** ត្រូវតែដោះស្រាយលក្ខខណ្ឌតម្រូវព័ត៌មានរបស់ក្រុមប្រឹក្សាភិបាល EFSB ភ្នាក់ងារអនុញ្ញាតថ្នាក់មូលដ្ឋាន ថ្នាក់តំបន់ និងថ្នាក់រដ្ឋ សមីសហគមន៍ និងភាគីពាក់ព័ន្ធផ្សេងទៀត។ [14] ដូចដែលបានកត់សម្គាល់ខាងលើ ពាក្យសុំរបស់ទីតាំង CEIF ត្រូវតែមានព័ត៌មានចាំបាច់សម្រាប់ការត្រួតពិនិត្យដោយភ្នាក់ងារអនុញ្ញាតថ្នាក់មូលដ្ឋាន ថ្នាក់តំបន់ និងថ្នាក់រដ្ឋនីមួយៗដែលជាធម្មតាមានយុត្តាធិការ ដើម្បីឱ្យពួកគេអាចផ្តល់សេចក្តីថ្លែងការណ៍អំពីលក្ខខណ្ឌលិខិតអនុញ្ញាតដែលបានណែនាំ និងមតិយោបល់ផ្សេងទៀតទៅកាន់ក្រុមប្រឹក្សាភិបាល EFSB ។ ដើម្បី បំពេញលក្ខខណ្ឌតម្រូវផ្នែកច្បាប់របស់ខ្លួន ក្រុមប្រឹក្សាភិបាល EFSB ក៏តម្រូវឱ្យមានប្រភេទព័ត៌មានជាក់លាក់ដែលមិនមែនសុទ្ធតែស្ថិតនៅក្នុងវិសាលភាពនៃកម្មវិធីផ្តល់លិខិតអនុញ្ញាតផ្សេងទៀតនោះទេ។ ព័ត៌មានដែលត្រូវការចាំបាច់នៅក្នុងពាក្យសុំរបស់ក្រុមប្រឹក្សាភិបាល EFSB **2.0** នឹងស្របគ្នានឹងការពង្រីកសិទ្ធិអំណាចត្រួតពិនិត្យរបស់ក្រុមប្រឹក្សាកំណត់ទីតាំង ដែលមានន័យថាឯកសារតម្កល់របស់ក្រុមប្រឹក្សា EFSB នឹងមានលក្ខណៈលម្អិតជាងអ្វីដែលបានឃើញនាពេលកន្លងមក។

បុគ្គលិកក្រុមប្រឹក្សាភិបាល EFSB បានពិនិត្យឡើងវិញនូវលក្ខខណ្ឌតម្រូវនៃការដាក់ពាក្យស្នើសុំរបស់រដ្ឋផ្សេងៗជាមួយនឹងលក្ខខណ្ឌកំណត់ការកំណត់ទីតាំងនិងអនុញ្ញាតស្រដៀងគ្នានេះសម្រាប់ទីតាំងថាមពល (<u>ឧ.</u> Michigan, New Hampshire, New York, Oregon, Rhode Island)។ ជាទូទៅ

---

14 ក្រុមប្រឹក្សាកំណត់ទីតាំងកត់សម្គាល់ថា ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 មិនបានលុបចោលច្បាប់អនុញ្ញាតសំខាន់ៗដែលមានស្រាប់ទេ ឧទាហរណ៍ ជំពូកទី 91 ជាដើម។ ពាក្យសុំលិខិតអនុញ្ញាតត្រូវតែនៅតែគោរពតាមច្បាប់ទាំងនេះ។ ក្រុមប្រឹក្សាកំណត់ទីតាំងក៏នឹងកំណត់ថាតើគម្រោងទាំងមូលបំពេញតាមលក្ខខណ្ឌកំណត់ច្បាប់លក្ខន្តិកៈរបស់ខ្លួននៅក្នុងច្បាប់ទូទៅ ជំពូក 164 ផ្នែក 69H ដែរឬអត់។

អាចនឹងមានវិធីសាស្រ្តសំខាន់ពីរសម្រាប់ការរៀបចំរចនាសម្ព័ន្ធពាក្យសុំរបស់ទីតាំងថាមពលដើម្បីស្វែងរកព័ត៌មានដែលចាំបាច់៖ (1) វិធីសាស្រ្ត "ការប្រមូលផ្តុំពាក្យសុំដែលមានស្រាប់", និង (2) វិធី សាស្រ្ត " ពាក្យសុំផ្អែកតាមគោលបំណង" ដែលត្រូវបានពិពណ៌នាខាងក្រោមថាជាជម្រើសដែលអាចមាន ដែលបំពេញតាមតម្រូវការរបស់ក្រុមប្រឹក្សាភិបាល EFSB **2.0** ។

1. <u>ការប្រមូលផ្តុំពាក្យសុំដែលមានស្រាប់ ("គំរូរួម")</u>

អនុលោមតាមគំរូរួម ពាក្យសុំរបស់ទីតាំង CEIF នឹងមានពីរផ្នែក៖ **(1)** "ផ្នែកវិសាលភាពទូលំទូលាយ" ដែលឆ្លុះបញ្ចាំងពីប្រភេទព័ត៌មានជា ធម្មតានៅក្នុងការដាក់ស្នើរបស់ការិយាល័យ MEPA និងឯកសារតម្កល់ដំបូងរបស់ក្រុមប្រឹក្សាភិបាល EFSB ។ និង **(2)** ផ្នែក "លក្ខខណ្ឌតម្រូវផ្សេងទៀតទាំងអស់" រួមទាំងពាក្យសុំលិខិតអនុញ្ញាត និងឯកសារតម្កល់ដែល ភ្នាក់ងាររដ្ឋ តំបន់ និងមូលដ្ឋានតម្រូវឱ្យមាន ប្រសិនបើក្រុមប្រឹក្សាភិបាល EFSB មិនចេញលិខិតអនុញ្ញាតនោះទេ។ ការកែលម្អជាក់លាក់នឹងត្រូវបានធ្វើឡើងនៅក្នុងពាក្យសុំរួមទាំងពីរផ្នែក ដូចជាការលុបបំបាត់ព័ត៌មានឥតបានការ និងការដោះស្រាយបញ្ហាបទប្បញ្ញត្តិដែលផ្ទុយគ្នា វិធីសាស្រ្ត និងស្តង់ដាដែលអាចមានក្នុងចំណោមកម្មវិធីលិខិតអនុញ្ញាតថ្នាក់រដ្ឋ ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋានផ្សេងៗ។ ឧទាហរណ៍អំពីគំរូរួមមានដូចជាដំណើរការចេញវិញ្ញាបនបត្ររបស់ក្រុមប្រឹក្សាភិបាល EFSB ដែលមានស្រាប់ អាជ្ញាប័ណ្ណរួមដែលចេញដោយក្រុមប្រឹក្សាភិបាលកំណត់ទីតាំងថាមពលរដ្ឋ Rhode Island និងវិញ្ញាបនបត្ររបស់គណៈកម្មាធិការ វាយតម្លៃទីតាំងរដ្ឋ New Hampshire ។

(a.) <u>ផ្នែកវិសាលភាពទូលំទូលាយ</u> នឹងគ្របដណ្តប់លើប្រធានបទដែលបានរួមបញ្ចូលចាស់ៗក្នុងពាក្យសុំរបស់ក្រុមប្រឹក្សាភិបាល EFSB ( <u>ឧ.</u> ការពិពណ៌នាគម្រោង តម្រូវការ វិធីសាស្ត្រគម្រោង ការជ្រើសរើសទីតាំង ផលប៉ះពាល់បរិស្ថាន ថ្លៃចំណាយ) ក៏ដូចជាលក្ខខណ្ឌតម្រូវថ្មីពីច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ **2024** (<u>ឧ.</u> ការវិភាគផលប៉ះពាល់ជាបន្តបន្ទាប់ និងការវិភាគភាពសមស្របរបស់ទីតាំង)។ បទប្បញ្ញត្តិនិងឯកសារណែនាំរបស់ក្រុមប្រឹក្សាភិបាល EFSB ថ្មីនឹងផ្តល់នូវភាពច្បាស់លាស់ និងសេចក្តីណែនាំកាន់តែច្រើនលើទម្រង់បែបបទនិង ខ្លឹមសារចាំបាច់នៃផ្នែកវិសាលភាពទូលំទូលាយ ដើម្បី សម្រេចបាននូវភាពស៊ីសង្វាក់គ្នាកាន់តែខ្លាំង បំពេញតាមស្តង់ដាលិខិតបទដ្ឋាននិងការរំពឹងទុក និងអនុញ្ញាតឱ្យការសម្រេចពេញលេញយ៉ាងឆាប់រហ័សនិងមានប្រសិទ្ធភាព។ ទោះជាយ៉ាងណាក៏ដោយ ការណែនាំនឹងមិនមានភាពតឹងរ៉ឹង ឬ "មានកំណត់"ខ្លាំងពេកនោះទេ ដើម្បីឱ្យអ្នកដាក់ពាក្យសុំមានភាពបត់បែនក្នុងការប្រគល់ជូនសម្ភារៈឯកសារដើម្បីគាំទ្រដល់សំណើរបស់ខ្លួន។

(b.) នៅក្នុងផ្នែក <u>"លក្ខខណ្ឌតម្រូវផ្សេងទៀតទាំងអស់"</u> អ្នកដាក់ពាក្យសុំចាំបាច់ត្រូវស្វែងរកលិខិតអនុញ្ញាត ការអនុម័ត និងការអនុញ្ញាតទាំងអស់ដែលភ្នាក់ងារថ្នាក់មូលដ្ឋាន ថ្នាក់តំបន់ និងថ្នាក់រដ្ឋតម្រូវឱ្យមានដែលអាចនឹងមានយុត្តាធិការសម្រាប់គម្រោងនោះ ក្នុងករណីក្រុមប្រឹក្សាភិបាល EFSB មិនមានសិទ្ធិចេញលិខិតអនុញ្ញាតដែលចាំបាច់ក្នុងការសាងសង់ និងដំណើរការគម្រោងមួយ។ អ្នកដាក់ពាក្យសុំនឹងចងក្រងជាប្រព័ន្ធ និងបញ្ជូនព័ត៌មាន ការអធិប្បាយ ទិន្នន័យ ផែនទី និងលក្ខណៈបច្ចេកទេស និងទម្រង់ពាក្យសុំដែលចាំបាច់សម្រាប់ភ្នាក់ងារចេញលិខិតអនុញ្ញាតថ្នាក់រដ្ឋ ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋាន។ លិខិតបទដ្ឋាននិងការណែនាំថ្មីរបស់ក្រុមប្រឹក្សាភិបាល EFSB នឹងណែនាំឱ្យអ្នកដាក់ពាក្យសុំផ្តល់នូវកញ្ចប់ពាក្យសុំពេញលេញសម្រាប់លិខិតអនុញ្ញាតនីមួយៗជាទម្រង់ដែលអាជ្ញាធរត្រួតពិនិត្យតម្រូវឱ្យមានជាធម្មតា។ ការណែនាំរបស់ក្រុមប្រឹក្សាភិបាល EFSB នឹងលើកទឹក ចិត្តអ្នកដាក់ពាក្យសុំឱ្យផ្ទៀងផ្ទាត់មើលលក្ខខណ្ឌតម្រូវព័ត៌មានឥតបានការនៅក្នុងពាក្យសុំនិងស្នើដំណោះស្រាយដែលបានស្នើលើលក្ខខណ្ឌតម្រូវដែលផ្ទុយគ្នាក្នុងចំណោមពាក្យសុំការអនុញ្ញាតផ្សេងៗ រួមទាំងភាពផ្ទុយគ្នាជាមួយនឹងបទប្បញ្ញត្តិកំណត់តំបន់។

2. <u>ពាក្យសុំស្តង់ដាថ្មី ("គំរូដែលបង្កើតឡើងក្នុងគោលបំណងជាក់លាក់")</u>

ផ្អែកតាម "គំរូដែលបង្កើតឡើងក្នុងគោលបំណងជាក់លាក់" ក្រុមប្រឹក្សាភិបាល EFSB នឹងបង្កើតពាក្យសុំស្តង់ដាមួយដើម្បីដោះស្រាយតម្រូវការព័ត៌មានផ្សេងៗរបស់ទីភ្នាក់ងារថ្នាក់រដ្ឋ ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋាន និងកម្មវិធីនានាដែលអាចនឹងមានយុត្តាធិការក្នុងការកំណត់ទីតាំងនិងអនុញ្ញាត លើគម្រោងរបស់ទីតាំង CEIF ។.[15] គោលដៅនៃគំរូដែលបង្កើតឡើងក្នុងគោលបំណងជាក់លាក់

---

[15] <u>សេចក្តីព្រាងលិខិតបទដ្ឋានទីតាំងបញ្ជូនថាមពលសំខាន់ៗដែលទើបនឹងស្នើឡើង</u> ដោយការិយាល័យកំណត់ថាមពលកកើតឡើងវិញ និងការបញ្ជូនចរន្ត អគ្គិសនីរបស់ទីក្រុង

គឺដើម្បីផ្តល់នូវបណ្តុំលក្ខខណ្ឌតម្រូវដាក់ពាក្យសុំតែមួយ រួមបញ្ចូលគ្នា និងទូលំទូលាយសម្រាប់ពាក្យ សុំរបស់ទីតាំង CEIF ដោយអនុលោមតាមលិខិតបទដ្ឋាន និងការណែនាំរបស់ក្រុមប្រឹក្សាភិបាល EFSB **2.0** ដោយពុំចាំបាច់ត្រូវបញ្ជូនពាក្យសុំលិខិតអនុញ្ញាតនីមួយៗដែលបានកំណត់ផ្សេងទៀតនោះទេ (ដូចបានរៀបរាប់នៅក្នុងគំរូរួម)។ គំរូដែលបង្កើតឡើងក្នុងគោលបំណងជាក់លាក់ ក៏នឹងរួម បញ្ចូលព័ត៌មានវិសាលភាពទូលំទូលាយដែលបានពិពណ៌នាខាងលើផងដែរ។

3. <u>ការពិចារណាក្នុងជម្រើសគំរូពាក្យសុំ</u>

ជម្រើសនៃគំរូពាក្យសុំគឺជាសំណួរជាមូលដ្ឋានមួយក្រុមប្រឹក្សាភិបាលកំណត់ទីតាំងត្រូវប្រឈមមុខដោះស្រាយសម្រាប់ដំណើរការបង្កើតវិធានដើម្បីអនុវត្តច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ **2024** ។ គុណសម្បត្តិនិងគុណវិបត្តិនៃវិធីសាស្ត្រទាំងពីរសម្រាប់ការរៀបចំរចនាសម្ព័ន្ធលក្ខខណ្ឌតម្រូវដាក់ពាក្យសុំ ត្រូវបានពិភាក្សាដូចខាងក្រោម។ សរុបមក បុគ្គលិកក្រុមប្រឹក្សាភិបាលកំណត់ទីតាំងពេញចិត្តចំពោះគំរូរួមជាងគំរូដែលបង្កើតឡើងក្នុងគោលបំណងជាក់លាក់ ដោយសារតែវាមានភាពសមស្របទៅនឹង៖ **(1)** ការប្រើប្រាស់ចំណេះជំនាញនៃកម្មវិធី/ភ្នាក់ងារអនុញ្ញាតដែលមានស្រាប់។ **(2)** ការផ្តល់ទិន្នន័យគម្រោងនិងព័ត៌មានចាំបាច់ជាទម្រង់ដែលធ្លាប់ស្គាល់ ដើម្បីជួយសម្រួលដល់ការត្រួតពិនិត្យរបស់ទីភ្នាក់ងារផ្សេងទៀតទៅលើពាក្យសុំ និងការបញ្ជូនពង្រាងលក្ខខណ្ឌលិខិតអនុញ្ញាត។ និង **(3)** ការឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរជាបន្តបន្ទាប់នៅក្នុងគោលនយោបាយនិងលក្ខខណ្ឌតម្រូពាក្យសុំលិខិតអនុញ្ញាតថ្នាក់រដ្ឋនិងមូលដ្ឋានផ្សេងទៀត ដោយគ្មានភាពយឺតយ៉ាវផ្នែកច្បាប់។ តាមទស្សនៈផ្នែករដ្ឋ បាល គំរូរួមក៏នឹងកាន់តែងាយបង្កើតនិងអនុវត្ត ដូច្នេះក៏ធានាកាន់តែខ្លាំងថានឹងបំពេញតាមកាល វេលាកំណត់នីតិបញ្ញត្តិសម្រាប់កម្មវិធីកំណត់ទីតាំងនិងអនុញ្ញាតថ្មី។ ពង្រាងសំណើគម្រោងរបស់បុគ្គលិកគឺត្រូវប្រើគំរូរួមដែលចាប់ផ្តើមនៅឆ្នាំ **2026** ហើយពិចារណានៅពេលក្រោយថាតើត្រូវផ្លាស់ទៅកាន់គំរូដែលបង្កើតឡើងក្នុងគោលបំណងជាក់លាក់ដែរឬទេ។

បញ្ហាធំមួយដែលអាចកើតមាននៃគំរូដែលបង្កើតឡើងក្នុងគោលបំណងជាក់លាក់គឺបណ្តាលមកពីលទ្ធផលសម្រេចដែលក្រុមប្រឹក្សាភិបាលតម្រូវឱ្យបង្កើតឡើង ពោលគឺលិខិតអនុញ្ញាតរួម ដែល គេបានកំណត់ថាជា "សមាសធាតុរួមផ្សំនៃរាល់លិខិតអនុញ្ញាត ការយល់ព្រម ឬការអនុញ្ញាតនីមួយៗដែលអាចនឹងចាំបាច់" ។ ខចែងដែលឆ្លុះបញ្ចាំងពីបទប្បញ្ញត្តិនៃសិទ្ធិអំណាចមានស្រាប់របស់ក្រុមប្រឹក្សាភិបាលក្នុងការចេញវិញ្ញាបនបត្រ តម្រូវឱ្យមានការយល់ព្រម ឬការអនុញ្ញាត<u>នីមួយៗ</u> ជំនួសឱ្យការយល់ព្រម ឬលិខិតអនុញ្ញាតទាំងឡាយដែលជាធម្មតាចេញដោយទីភ្នាក់ងាររដ្ឋនិងមូលដ្ឋានផ្សេងទៀតដែលមានយុត្តាធិការ។ ការដាក់បញ្ចូលការយល់ព្រមនីមួយៗនៅក្នុងវិញ្ញាបនបត្រ (ឬនៅក្នុងលិខិតអនុញ្ញាតរួមនាពេលអនាគត) ក៏ជួយសម្រួលដល់ការអនុវត្តបទប្បញ្ញត្តិនេះដោយទីភ្នាក់ងារដែលជាធម្មតាមានយុត្តាធិការលើបញ្ហានេះ។ [16] ពាក្យសុំដែលបង្កើតឡើងក្នុងគោលបំណងជាក់លាក់ អាចបង្ហាញថាគ្មានប្រសិទ្ធភាពដោយសារតែវាញែកព័ត៌មានដែលប្រមូលបានពីឯកសារផ្ទាល់ខ្លួនរបស់កម្មវិធីអនុញ្ញាតមូលដ្ឋានដើម្បីបង្កើតការអនុម័តឡើងវិញដែលមានលក្ខណៈដូចគ្នាខ្លាំងទៅនឹងលិខិតអនុញ្ញាតដែលមានស្រាប់របស់ទីភ្នាក់ងារទាំងនោះនៅក្នុងលិខិតអនុញ្ញាតរួមរបស់ក្រុមប្រឹក្សាភិបាល។

**តារាងទី1៖ គុណសម្បត្តិនិងគុណវិបត្តិនៃគំរូសម្រាប់ការកំណត់រចនាសម្ព័ន្ធលក្ខខណ្ឌតម្រូវពាក្យសុំ**

| **គំរូ** | **គុណសម្បត្តិ** | **គុណវិបត្តិ** |
|---|---|---|
| គំរូរួម | • ពាក្យសុំលិខិតអនុញ្ញាតដែលមាន | • ត្រូវការផ្តល់ការណែនាំជាក់ លាក់ |

ញ់វយ៉ក ផ្តល់នូវឧទាហរណ៍ស្តីពីវិធីសាស្ត្រ "បង្កើតឡើងក្នុងគោលបំណងជាក់លាក់" ដែលបង្កើតនូវបណ្តុំលក្ខខណ្ឌតម្រូវពាក្យសុំតែមួយ។ ទោះបីជាគណៈកម្មាធិការសេវាសាធារណៈរដ្ឋ Wisconsin មិនចេញសេចក្តី អនុម័តរួមជូនដល់ទីតាំងថាមពលដែលមានសិទ្ធិទទួលបានក៏ដោយ ប៉ុន្តែវាគឺជាឧទាហរណ៍មួយទៀតស្តីពីវិធីសាស្ត្រ "បង្កើតឡើងក្នុងគោលបំណងជាក់លាក់" សម្រាប់ លក្ខខណ្ឌតម្រូវពាក្យសុំដែលបែងចែកខុសគ្នាតាមប្រភេទទីតាំងគ្រឹះស្ថាន។

16 **ច្បាប់នេះប្រគល់ការអនុវត្តលក្ខខណ្ឌលិខិតអនុញ្ញាតត្រឡប់ទៅកាន់ទីភ្នាក់ងារអនុញ្ញាត។ ច្បាប់លក្ខន្តិកឆ្នាំ 2024 ជំពូក 239 ផ្នែក 74**

| គំរូ | គុណសម្បត្តិ | គុណវិបត្តិ |
|---|---|---|
| | ស្រាប់ ប្រមូលព័ត៌មានចាំបាច់រួចរាល់សម្រាប់ការពិនិត្យនិងអនុម័ត។ ការតម្រូវឱ្យអ្នកដាក់ពាក្យសុំរួមបញ្ចូលទម្រង់ពាក្យសុំដែលមានស្រាប់សម្រាប់លិខិតអនុញ្ញាតថ្នាក់រដ្ឋនិងមូលដ្ឋានដែលចាំបាច់ នឹងជួយឱ្យទីភ្នាក់ងារផ្សេងទៀតពិនិត្យមើលភាពពេញលេញ និងផ្តល់នូវសេចក្តីព្រាងលក្ខខណ្ឌលិខិត អនុញ្ញាត។ សូម្បីតែមានការលុបបំ បាត់ព័ត៌មានឥតបានការក៏ដោយ ក៏ដំណើរការសិក្សាស្វែងយល់សម្រាប់អ្នកដាក់ពាក្យសុំគម្រោងអាចនឹងមាន រយៈពេលខ្លីជាងមុនដែរ។<br>• ពឹងផ្អែកលើវិធាន លិខិតបទដ្ឋាន និងកម្មវិធីអនុញ្ញាតដែលមានពីមុនរបស់រដ្ឋ និងមូលដ្ឋាន។<br>• ធានាថាលក្ខខណ្ឌតម្រូវពាក្យសុំទីតាំង CEIF នៅតែមានព័ត៌មានថ្មីៗ ខណៈដែលលក្ខខណ្ឌតម្រូវលិខិតអនុញ្ញាត ថ្នាក់រដ្ឋនិងមូលដ្ឋានមានការវិវត្តប្រែប្រួល។<br>• អាចជួយជៀសវាងការសម្រេចចិត្តលើពាក្យសុំរួមដែលមិន "ពេញលេញ"។<br>• មានប្រសិទ្ធិភាពផ្នែករដ្ឋបាលក្នុងការ បង្កើត បើប្រៀបធៀបទៅនឹង "ពាក្យសុំដែលបង្កើតឡើងក្នុងគោលបំណង ជាក់លាក់"។ | ដើម្បីកាត់បន្ថយព័ត៌មានស្ទួនដែលចាំបាច់ត្រូវបំពេញក្នុងពាក្យសុំលិខិតអនុញ្ញាត ច្រើនលើសពីមួយ។<br>• ក្រុមប្រឹក្សាភិបាល EFSB 2.0 ប្រហែលជាត្រូវដោះស្រាយ បង្ហាញលក្ខខណ្ឌផ្ទុយគ្នារវាងរវាងពាក្យសុំលិខិតអនុញ្ញាត ផ្សេងៗ។<br>• អ្នកដាក់ពាក្យអាចនឹងគិតថាដំណើរការនៃការផ្តល់ពាក្យសុំលិខិតអនុញ្ញាតទាំងអស់ ដែលតម្រូវចាំបាច់ផ្សេងទៀតជាទម្រង់ដែលអាជ្ញាធរត្រួតពិនិត្យជម្មតាណាមួយបានតម្រូវឱ្យមាននោះគឺជាបន្ទុកធ្ងន់ធ្ងរ។ |
| គំរូដែលបង្កើតឡើងក្នុងគោលបំណងជាក់លាក់ | • បង្កើតបណ្តុំលក្ខខណ្ឌតម្រូវពាក្យសុំ CEIF តែមួយដែលបង្កើតឡើងដើម្បីប្រមូលព័ត៌មានទាំងអស់ដែលចាំបាច់ ដើម្បីបំពេញរាល់លក្ខខណ្ឌតម្រូវផ្លូវច្បាប់នៃលិខិតអនុញ្ញាតនីមួយៗ ដែលរួមបញ្ចូលនៅក្នុងការអនុម័តរួមរបស់ក្រុមប្រឹក្សាភិបាល EFSB ។<br>• តម្រូវជាជម្មតាឱ្យលុបបំបាត់/កាត់បន្ថយលក្ខខណ្ឌតម្រូវស្ទួន និងដោះ | • តម្រូវឱ្យមានធនធានច្រើន និងទីភ្នាក់ងារនិងចំណេះជំនាញខាងពិគ្រោះយោបល់ផ្សេងៗជាច្រើន ដើម្បីសំយោគពាក្យសុំលិខិតអនុញ្ញាត (សូមមើលឧបសម្ព័ន្ធ A) លក្ខខណ្ឌតម្រូវលិខិតបទដ្ឋាន និងកម្មវិធីជាច្រើនរួមបញ្ចូលគ្នាទៅក្នុងសំណុំលក្ខខណ្ឌតម្រូវពាក្យសុំ CEIF តែមួយ ដែលនឹងដំណើរការសម្រាប់អ្នកត្រួតពិនិត្យទាំងអស់, អាចធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តទាន់ពេលវេលានូវលក្ខខណ្ឌតម្រូវនៃច្បាប់បម្រែបម្រួល |

| គំរូ | គុណសម្បត្តិ | គុណវិបត្តិ |
|---|---|---|
| | ស្រាយបញ្ហាភាពផ្ទុយគ្នាដែលអាចកើតមានរវាងពាក្យសុំលិខិតអនុញ្ញាតថ្នាក់រដ្ឋ និងពាក្យសុំថ្នាក់មូលដ្ឋាន។<br>• ផ្តល់ឱ្យអ្នកដាក់ពាក្យសុំនូវលក្ខខណ្ឌតម្រូវដែលស្របគ្នា។ | អាកាសធាតុឆ្នាំ 2024 ។<br>• អ្នកត្រួតពិនិត្យរបស់ទីភ្នាក់ងារ (និងភាគីពាក់ព័ន្ធ) អាចគិតថាមិនធ្លាប់ស្គាល់ពាក្យសុំនេះ ឬពាក្យសុំនេះមានប្រយោជន៍ចំពោះផលប្រយោជន៍និងតម្រូវការជាក់លាក់របស់ពួកគេតិចតួចជាងពាក្យសុំដែលមានស្រាប់ដែលកំពុងដាក់ឱ្យប្រើប្រាស់រួចហើយ។ អ្នកដាក់ពាក្យសុំគម្រោងក៏នឹងត្រូវសិក្សាអំពីបណ្តុំលក្ខខណ្ឌតម្រូវថ្មីនេះផងដែរ។<br>• ការបន្តធ្វើបច្ចុប្បន្នភាពព័ត៌មានពាក្យសុំដែលបង្កើតឡើងក្នុងគោលបំណងជាក់លាក់ នឹងក្លាយជាបញ្ហាប្រឈមជាបន្តបន្ទាប់នៅពេលដែលលក្ខខណ្ឌតម្រូវនៃលិខិតអនុញ្ញាតថ្នាក់រដ្ឋនិងមូលដ្ឋានមានការវិវត្តប្រែប្រួល។<br>• ការសម្រេចចិត្តលើការអនុម័តនឹងតម្រូវឱ្យក្រុមប្រឹក្សាភិបាលធ្វើការញែកព័ត៌មានពាក្យសុំប្រកបដោយប្រសិទ្ធភាព ត្រឡប់ទៅជាលិខិតអនុញ្ញាតនីមួយៗដាច់ដោយឡែកវិញ ផ្អែកតាមនិយមន័យនៃលិខិតអនុញ្ញាតរួម និងការអនុវត្តរបស់ភ្នាក់ងារដែលមានយុត្តាធិការលើបញ្ហានេះ។ នេះនឹងបង្កើតការងារបន្ថែម និងភាពគ្មានប្រសិទ្ធភាព។ |

B. *ស្តង់ដារប្រើប្រាស់ក្នុងពាក្យសុំរបស់ក្រុមប្រឹក្សាភិបាល EFSB*

**មកទល់ពេលនេះ លក្ខខណ្ឌតម្រូវពាក្យសុំរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបានរួមបញ្ចូលឧទាហរណ៍មួយចំនួនអំពីស្តង់ដារអនុលោមតាមលិខិតបទដ្ឋានជាតួលេខជាក់លាក់ ដែលកំណត់ព្រំដែនផលប៉ះពាល់បរិស្ថាន ឬផលប៉ះពាល់ប្រភេទផ្សេងទៀត “ស្របតាមច្បាប់”។[17] ផ្ទុយទៅវិញ នៅក្នុងការវិនិច្ឆ័យរបស់ខ្លួន ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងជាទូទៅពឹងផ្អែកលើស្តង់ដារលិខិតបទដ្ឋានដែលបង្កើតឡើងដោយទីភ្នាក់ងារសហព័ន្ធ រដ្ឋ និងមូលដ្ឋាន ឬស្ថាប័នកំណត់ស្តង់ដារដែលបានទទួលស្គាល់។ ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 ណែនាំក្រុមប្រឹក្សាភិបាលឱ្យបង្កើតលក្ខណៈវិនិច្ឆ័យដែលគ្រប់គ្រងការកំណត់ទីតាំង និងការអនុញ្ញាតឱ្យទីតាំង LCEIF និង SCEIF ដែលរួមមាន "បណ្តុំ**

[17] **មានលិខិតបទដ្ឋានរបស់ក្រុមប្រឹក្សាភិបាល EFSB មួយចំនួនដែលកំណត់មូលដ្ឋានគោលជាតួលេខជាក់លាក់។ ឧទាហរណ៍ ស្តង់ដារអនុវត្តបច្ចេកវិទ្យាបង្កើតដែនកំណត់ជាក់លាក់នៃការបំភាយផ្សែងពលសម្រាប់ទីតាំងរោងចក្រផលិតថាមពលហ្វូស៊ីលដែលសន្មត់ថាម្ចាស់សំណើបានបញ្ចូល "លក្ខណៈនៃការអនុវត្តបច្ចេកវិទ្យា បរិស្ថានទំនើបបំផុត"។ ក្រមបញ្ញត្តិរដ្ឋម៉ាសាជូសិត (CMR) មាត្រា 980 ផ្នែក 12.01(1)(e). លិខិតបទដ្ឋានរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងសម្រាប់ការកំណត់ទីតាំងស្តុកទុកឧស្ម័នធម្មជាតិរាវក្នុងរដ្ឋ ក៏មានដែនកំណត់ជាតួលេខជាក់លាក់ និងស្តង់ដារទាក់ទងនឹងប៉ារ៉ាម៉ែត្រដែលទាក់ទងនឹងសុវត្ថិភាពជាច្រើនសម្រាប់ទីតាំងទាំងនេះ។ ក្រម CMR មាត្រា 980 ផ្នែក 10.00.**

ស្តង់ដាសុវត្ថិភាពសុខភាពមូលដ្ឋាន បរិស្ថាន និងស្តង់ដាផ្សេងទៀតដែលអនុវត្តចំពោះបញ្ហានៃលិខិតអនុញ្ញាតរួម។" ច្បាប់ទូទៅ ជំពូក **164** ផ្នែក **69**T(b) ផ្នែក **69**U(b) និងផ្នែក **69**V(b).

ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ **2024** រួមបញ្ចូលបទប្បញ្ញត្តិផ្សេងទៀតដែលនឹងបង្កើត ស្តង់ដា និងលក្ខណៈវិនិច្ឆ័យថ្មីដែលត្រូវដាក់បញ្ចូលក្នុងដំណើរការរបស់ក្រុមប្រឹក្សាភិបាល EFSB **2.0** និងពាក្យសុំដែលបានដាក់ជូនក្រុមប្រឹក្សាភិបាល។ ឧទាហរណ៍ ការិយាល័យប្រតិបត្តិកិច្ចការថាមពល និងបរិស្ថាន ("EEA") មានភារកិច្ចបង្កើតលក្ខណៈវិនិច្ឆ័យភាពសមស្របនៃទីតាំង ដើម្បីវាយតម្លៃផលប៉ះពាល់សង្គមនិងបរិស្ថាននៃទីតាំងគម្រោងរបស់ CEIF ដែលរួមមានឋានានុក្រមកាត់បន្ថយផលប៉ះពាល់ ដើម្បីជៀសវាង កាត់បន្ថយ និងបន្ធូរបន្ថយផលប៉ះពាល់នៃការកំណត់ទីតាំងគ្រឹះស្ថានទាំង នេះ។ ច្បាប់ទូទៅ ជំពូក **164** ផ្នែក **69**T. ម្យ៉ាងវិញទៀត ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងតម្រូវឱ្យបង្កើតស្តង់ដាសម្រាប់ការអនុវត្តលក្ខណៈវិនិច្ឆ័យភាពសមស្របនៃទីតាំង។ ការិយាល័យ EEA នៃ ការិយាល័យ យុត្តិធម៌និងសមធម៌បរិស្ថាន នឹងបង្កើតស្តង់ដានិងគោលការណ៍ណែនាំសម្រាប់អ្នក ដាក់ពាក្យសុំដែលធ្វើការវិភាគផលប៉ះពាល់រួម ជាមួយនឹងលិខិតបទដ្ឋានដែលបានប្រកាសឱ្យប្រើចាប់ ពីពេលនោះតទៅ ដោយក្រុមប្រឹក្សាភិបាលកំណត់ទីតាំងដែលអនុវត្តស្តង់ដានិងគោលការណ៍ណែនាំទាំង នេះ។ ច្បាប់ទូទៅ ជំពូក **164** ផ្នែក **69**T. នាយកដ្ឋាន DOER មានភារកិច្ចបង្កើតស្តង់ដា លក្ខខណ្ឌតម្រូវ និងនីតិវិធីទាក់ទងនឹងទីតាំង និងការអនុញ្ញាតគម្រោងរបស់ SCEIF ដែលក្នុងករណី ខ្លះអាចនាំទៅកាន់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងសម្រាប់ការត្រួតពិនិត្យការវិនិច្ឆ័យ។ ច្បាប់ទូទៅ ជំពូក **25**A ផ្នែក **21**, ច្បាប់ទូទៅ ជំពូក **164** ផ្នែក **69**W.

ជាផ្នែកមួយនៃដំណើរការបង្កើតពាក្យសុំ ក្រុមប្រឹក្សាភិបាលអាចជ្រើសរើសផ្តល់នូវភាពជាក់លាក់កាន់តែខ្លាំងទាក់ទងនឹង សុខភាព សុវត្ថិភាព បរិស្ថាន និងស្តង់ដាផ្សេងទៀត ដែលអនុវត្តចំពោះបញ្ហានៃលិខិតអនុញ្ញាតរួម។ លើសពីនេះ ពាក្យសុំរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង អាចបង្កើតគោលការណ៍ណែនាំទូទៅ ឬវិធីសាស្ត្រលម្អិតបន្ថែមទៀត ដើម្បីឱ្យអ្នកដាក់ពាក្យសុំប្រើប្រាស់ក្នុងការសិក្សានិងវិភាគប្រភេទផ្សេងៗ ដើម្បីវាយតម្លៃផលប៉ះពាល់សុខភាព សុវត្ថិភាព និងបរិស្ថាន។ ពិតមែនតែរដ្ឋមួយចំនួនដែលបានស្ទង់មតិបានរួមបញ្ចូលនូវបទប្បញ្ញត្តិលម្អិតទាំងនេះដោយផ្ទាល់ទៅក្នុងពាក្យសុំការកំណត់ទីតាំងនិងការអនុញ្ញាតយ៉ាងណាក្តី ក៏ការណ៍នេះនឹងបន្ថែមភាពស្មុគស្មាញសម្រាប់ពាក្យសុំ EFSB **2.0** ។

យើងស្វាគមន៍រាល់មតិយោបល់ថាតើមានភាពសមស្របក្នុងការប្រើប្រាស់ដំណើរការបង្កើតពាក្យសុំនោះដែរឬទេ ដើម្បីឱ្យក្រុមប្រឹក្សាភិបាលកំណត់ស្តង់ដាផលប៉ះពាល់ផ្នែកសុខភាព សុវត្ថិភាព បរិស្ថានជាក់លាក់ និងស្តង់ដាផលប៉ះពាល់គម្រោងផ្សេងទៀត ឬកំណត់ខ្លួនឯងត្រឹមកម្រិតស្តង់ដាមានស្រាប់ដែលកំពុងប្រើប្រាស់ស្រាប់។ ដោយឡែក យើងក៏សូមស្វាគមន៍មតិយោបល់ផងដែរថាតើដំណើរការបង្កើតពាក្យសុំគួរតែបង្កើតនីតិវិធីវិភាគ វិធីសាស្ត្រ ឬអភិក្រមសម្រាប់កំណត់ការអនុលោមតាមគម្រោងដែលបានស្នើឡើងជាមួយនឹងស្តង់ដាសុខភាព សុវត្ថិភាព បរិស្ថាន ឬស្តង់ដាផលប៉ះពាល់គម្រោងផ្សេងទៀតដែរឬទេ។ បើដូច្នេះមែន តើនីតិវិធី វិធីសាស្ត្រ និងអភិក្រមទាំងនេះតម្រូវឱ្យមានដែរទេ ឬក៏គ្រាន់តែជាការណែនាំទេ?

C. *ការកែលម្អផ្នែក "វិសាលភាពទូលំទូលាយ" នៃពាក្យសុំរបស់ក្រុមប្រឹក្សាភិបាល* EFSB

ក្រុមប្រឹក្សាភិបាល EFSB នឹងបង្កើតលក្ខខណ្ឌតម្រូវដែលរៀបរាប់លម្អិតអំពីខ្លឹមសារនៃផ្នែកពាក្យសុំនីមួយៗ រួមទាំងលក្ខខណ្ឌតម្រូវថ្មីៗពីច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ **2024** ។ ខាងក្រោមនេះគឺជាបញ្ជីរាយនាមផ្នែកពាក្យសុំសំខាន់ៗ ក៏ដូចជាគោលបំណងរបស់ក្រុមប្រឹក្សា EFSB ដំបូងក្នុងការធ្វើផ្នែកទាំងនោះឱ្យមានលក្ខណៈស្តង់ដា៖

- ការពិពណ៌នាអំពីគម្រោង ទីតាំង និងតំបន់ជុំវិញ៖ ក្រុមប្រឹក្សាភិបាល EFSB មានបំណងបង្កើតលក្ខខណ្ឌតម្រូវដែលធ្វើឱ្យព័ត៌មានគម្រោងមូលដ្ឋាន បរិការណ៍ និងការពិតដែលអ្នកដាក់ពាក្យស្នើសុំផ្តល់នៅក្នុងផ្នែកដំបូងនៃពាក្យសុំរបស់ទីតាំង CEIF ។ ធ្វើដូច្នេះអាចនឹងនាំឱ្យមានមានទម្រង់បែបបទស្តង់ដាតាមប្រភេទទីតាំង CEIF (**ឧ. ការបញ្ជូននិងចែកចាយ ការបង្កើត ការផ្ទុកថាមពល)។**

- **ការពិគ្រោះយោបល់ជាមុន និងការចូលរួមក្នុងសហគមន៍៖** ទីតាំង EFSB និងនាយកដ្ឋាន DPU កំពុងរួមគ្នាបង្កើតបណ្តុំស្តង់ដានៃលក្ខខណ្ឌតម្រូវសម្រាប់ការពិគ្រោះយោបល់មុនដាក់ពាក្យសុំ និងការចូលរួមក្នុងសហគមន៍ដែលបានតម្រូវតាមច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 ។ ពាក្យស្នើសុំរបស់ទីតាំង CEIF នឹងរួមបញ្ចូលសេចក្តីសង្ខេប ឬសេចក្តីអធិប្បាយខ្លីៗទាក់ទងនឹងការបញ្ចប់សកម្មភាពមុនដាក់ពាក្យសុំ។ (សូមមើលពាង្រាងសំណើគម្រោងរបស់បុគ្គលិក ការពិគ្រោះយោបល់និងការចូលរួមរបស់បុគ្គលិកពាង្រាងសំណើគម្រោង ដើម្បីទទួលបានព័ត៌មានបន្ថែម)

- **តម្រូវការគម្រោង និងអត្ថប្រយោជន៍ថាមពល:** សម្រាប់ទីតាំងរោងចក្របញ្ជូននិងចែកចាយថាមពល ក្រុមប្រឹក្សាភិបាលមានបំណងបង្កើតលក្ខខណ្ឌតម្រូវដែលយោងការអនុវត្តដែលមានស្រាប់សម្រាប់បង្ហាញពីតម្រូវការគម្រោងដែលបានបង្កើតឡើងតាមរយៈករណីពីមុនមករបស់ក្រុមប្រឹក្សាភិបាល EFSB ។ ការអនុវត្តទាំងនេះរួមមានការពិពណ៌នា៖ (1) លក្ខណៈវិនិច្ឆ័យនៃការរៀបចំប្រព័ន្ធបញ្ជូននិងចែកចាយថាមពលដែលពាក់ព័ន្ធ (2) វិធីសាស្ត្រដែលបានប្រើសម្រាប់ការវាយតម្លៃភាពជឿជាក់នៃប្រព័ន្ធ (រួមទាំងការព្យាករណ៍បន្ទុក) និង (3) ថាតើប្រព័ន្ធអគ្គិសនីដែលមានស្រាប់ត្រូវគ្នានឹងលក្ខណៈ វិនិច្ឆ័យដែលអាចទុកចិត្តបាននៅក្រោមស្ថានភាពពេលវេលាមានតម្រូវការថាមពលខ្ពស់ និងស្ថានភាពគ្រាអាសន្នក្នុងរយៈពេលព្យាករណ៍ដែរឬអត់។

- **ការពិពណ៌នាអំពីអត្ថប្រយោជន៍ថាមពល៖** ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 តម្រូវឱ្យពាក្យសុំរបស់ LCEG និង LCES រួមបញ្ចូលនូវ "ការពិពណ៌នាអំពីអត្ថប្រយោជន៍ ថាមពល" (មើល ច្បាប់ទូទៅ ជំពូក 164 69T(d)(i)))។ លក្ខខណ្ឌតម្រូវថ្មីសម្រាប់ពាក្យសុំរបស់ក្រុមប្រឹក្សាភិបាល EFSB នឹងរៀបរាប់លម្អិតអំពីប្រភេទព័ត៌មានដែលអ្នកដាក់ញត្តិស្នើសុំ គួរតែផ្តល់ដើម្បីចងក្រងឯកសារ "អត្ថប្រយោជន៍ថាមពល" ។

- **ជម្រើសជំនួសគម្រោង៖** សម្រាប់ទីតាំងបញ្ជូននិងចែកចាយថាមពល ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងមានបំណងបង្កើតលក្ខខណ្ឌតម្រូវពាក្យសុំដែលផ្អែកតាមការសម្រេចចិត្តពីមុនរបស់ក្រុមប្រឹក្សាភិបាល EFSB សម្រាប់ការវាយតម្លៃជម្រើសគម្រោង។ លក្ខខណ្ឌតម្រូវដែលបានស្នើសុំរបស់ក្រុមប្រឹក្សាភិបាល EFSB 2.0 ក៏នឹងបញ្ជាក់យ៉ាងលម្អិតអំពីការណែនាំរបស់ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 ដែលក្រុមប្រឹក្សាភិបាលកំណត់ទីតាំងវិភាគទៅលើគ្រឿងបញ្ជូនចរន្តកម្រិតខ្ពស់ បច្ចេកវិទ្យាបញ្ជូនចរន្តកម្រិតខ្ពស់ បច្ចេកវិទ្យាពង្រឹងបណ្តាញថាមពលអគ្គិសនី និងជម្រើសដែលឥតប្រើខ្សែ។

- **ការជ្រើសរើសផ្លូវ និងការជ្រើសរើសទីតាំង៖** ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងនឹងកែលម្អ ការអនុវត្តការដាក់ពិន្ទុវាយតម្លៃជាតួលេខរបស់ខ្លួនសម្រាប់ដំណើរការជ្រើសរើសផ្លូវនិង ទីតាំងដោយការដាក់បញ្ចូលនូវឧត្តមានុវត្តនៅក្នុងលិខិតបទដ្ឋាននិងការណែនាំ ហើយរួមបញ្ចូលធាតុថ្មីមួយចំនួន ដូចជាលក្ខណៈវិនិច្ឆ័យភាពសមស្របនៃទីតាំងនាពេលខាងមុខរបស់ការិយាល័យ EEA និងលក្ខណៈវិនិច្ឆ័យនៃការវិភាគផលប៉ះពាល់ ("CIA") ដែលកំពុងត្រូវបានបង្កើតឡើងដោយការិយាល័យ EEA នៃការិយាល័យ "ប្រឹក្សាយុត្តិធម៌និងសមធម៌បរិស្ថាន" ("OEJE") បុគ្គលិករបស់ក្រុមប្រឹក្សាភិបាល EFSB ដោយមានការពិគ្រោះ យោបល់ជាមួយទីភ្នាក់ងារនិងការិយាល័យ EEA។

- **ផលប៉ះពាល់បរិស្ថាន** ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងមានបំណងបង្កើតបណ្តុំស្តង់ដានៃប្រភេទផលប៉ះពាល់បរិស្ថានសម្រាប់ប្រើប្រាស់នៅក្នុងពាក្យសុំរបស់ CEIF ទាំងអស់។ លក្ខខណ្ឌតម្រូវពាក្យសុំទំនងជានឹងបែងចែកវិសាលភាពនៃការវិភាគដែលតម្រូវចាំបាច់ សម្រាប់ប្រភេទផលប៉ះពាល់នីមួយៗតាមប្រភេទនៃទីតាំងគ្រឹះស្ថានដែលបានស្នើឡើង (ឧ. ការស្តុកទុក ការបញ្ជូនថាមពលព្រះអាទិត្យ ខ្យល់)។ ផ្នែកនេះអាចរួមបញ្ចូលស្តង់ដាជាក់លាក់ និងវិធីសាស្ត្រវិភាគ ដូចបានពិពណ៌នាខាងលើ។

- **ការវិភាគផលប៉ះពាល់រួម** ពាក្យសុំនឹងរួមបញ្ចូលព័ត៌មានរបស់ CIA សម្រាប់ទីតាំង គ្រឹះស្ថានដែលបានស្នើឡើងទាំងអស់ ដូចបានរៀបរាប់នៅក្នុងស្តង់ដា និងការណែនាំពីការិយាល័យ

EEA OEJE និងលិខិតបទដ្ឋាននិងការណែនាំនាពេលខាងមុខរបស់ក្រុមប្រឹក្សាលើប្រធានបទនេះ។

- គោលនយោបាយរបស់រដ្ឋម៉ាសាឈូសិត ក្រុមប្រឹក្សាកំណត់ទីតាំងមានបំណងបង្កើត លិខិតបទដ្ឋាននិងការណែនាំដែលឆ្លុះបញ្ចាំងពីការអនុវត្តដែលបានណែនាំសម្រាប់ការវិភាគការអនុលោមតាមគម្រោងជាមួយនឹងគោលនយោបាយរបស់រដ្ឋម៉ាសាឈូសិត។

- សំណើសុំលើកលែងការកំណត់តំបន់៖ ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 ផ្ទេរសិទ្ធិអំណាចលើកលែងការកំណត់តំបន់របស់នាយកដ្ឋាន DPU ទៅឱ្យក្រុមប្រឹក្សាភិបាល EFSB និងបញ្ជាក់ពីសិទ្ធិទទួលបានរបស់ខ្លួនដោយកំណត់ "សាជីវកម្មសេវាសាធារណៈ" យ៉ាងទូលំទូលាយ ដើម្បីរួមបញ្ចូលនូវទីតាំងថាមពលនិងម្ចាស់សំណើជាច្រើនទៀត។ លក្ខខណ្ឌតម្រូវរបស់ក្រុមប្រឹក្សាភិបាល EFSB 2.0 នឹងដោះស្រាយប្រភេទព័ត៌មានដែល ត្រូវការ ចាំបាច់សម្រាប់សំណើលើកលែងការកំណត់តំបន់ ថាតើបានស្វែងរកដោយខ្លួនឯង ឬ ដោយភ្ជាប់ជាមួយសំណើសុំលិខិតអនុញ្ញាតរួមដែរឬអត់។ ស្តង់ដាត្រួតពិនិត្យសម្រាប់លើកលែងការកំណត់តំបន់គឺទូលំទូលាយ ហើយព័ត៌មានដែលចាំបាច់គឺស្រដៀងគ្នាភាគច្រើនទៅនឹងការអនុម័តបច្ចុប្បន្នរបស់ក្រុមប្រឹក្សាភិបាលដើម្បីសាងសង់ករណីណាមួយ។

- ការរៀបចំ និងការដាក់បញ្ជូនវីដេអូទិដ្ឋភាពទូទៅនៃគម្រោង៖ ក្រុមប្រឹក្សា EFSB កំពុងពិចារណារួមបញ្ចូលលក្ខខណ្ឌតម្រូវដើម្បីឱ្យអ្នកដាក់ពាក្យសុំបំពេញបន្ថែមសម្ភារៈឯកសារពាក្យសុំជាលាយលក្ខណ៍អក្សរជាមួយនឹងវីដេអូសង្ខេបអំពីគម្រោង (5-10 នាទី)។ ការណែនាំនឹងបញ្ជាក់អំពីប្រភេទព័ត៌មានជាក់ស្តែង ពាក្យសម្ដីបែបអព្យាក្រឹត ក្រាហ្វិក និងលក្ខណៈពិសេសផ្សេងទៀតនៅក្នុងវីដេអូ ដែលនឹងជួយដល់សមាជិកសាធារណៈដែលចាប់អារម្មណ៍ ចង់ទទួលបានការយល់ដឹងអំពីគម្រោងនេះ ដោយជៀសវាងការបញ្ចេញសំឡេង "ការតស៊ូមតិបែបទីផ្សារ" សម្រាប់គម្រោងដែលបានស្នើឡើង។ វីដេអូពាក់ព័ន្ធនឹងពាក្យសុំ ជារូប ភាពបង្ហាញ (ផលិតដោយក្រុមហ៊ុនបណ្តាញអគ្គិសនីជាតិ (National Grid) សម្រាប់គម្រោងបញ្ជូននិងចែកចាយថាមពល អាចទស្សនាបាននៅលើ https://shorturl.at/Uj7OI, និង

- មុខងារពិសេសសម្រួលដល់ការប្រើប្រាស់ ដោយអនុលោមតាមគោលបំណងនៃការចូលរួមជាសាធារណៈ និងការចូលរួមរបស់ក្រុមប្រឹក្សាភិបាល EFSB លិខិតបទដ្ឋាននិងការណែនាំអំពីការដាក់ពាក្យសុំ ផែនការចូលប្រើភាសានឹងដោះស្រាយបញ្ហាទម្រង់ឯកសារនិងលក្ខណៈបច្ចេកទេសដែលអំណោយផលដល់តម្រូវការបកប្រែភាសាជាឯកសារ និងការបកប្រែផ្ទាល់មាត់ និងការអនុលោមតាមច្បាប់ជនពិការអាមេរិក ("ADA") ។ ក្រុមប្រឹក្សាកំណត់ទីតាំងក៏ចាប់អារម្មណ៍ចង់ស្វែងយល់ពីវិធីដែលទម្រង់ពាក្យសុំនិងលក្ខណៈបច្ចេកទេសអាចបង្កើនការប្រើប្រាស់ឧបករណ៍វិភាគបែបបញ្ញានិម្មិត ("AI") ឬបច្ចេកវិទ្យាផ្សេងទៀតដែលលើកកម្ពស់ទំនាក់ទំនងនិងការចូលរួមជាសាធារណៈ ព្រមទាំងប្រសិទ្ធភាពនិងប្រសិទ្ធផលនៃដំណើរការទាំងមូល។

D. *ការវិនិច្ឆ័យសាជាថ្មីអនុលោមតាមច្បាប់ទូទៅ ជំពូក 164 ផ្នែក 69W*

ដូចបានកត់សម្គាល់ខាងលើ ច្បាប់ទូទៅ ជំពូក 164 ផ្នែក 69W អាចនាំឱ្យក្រុមប្រឹក្សាភិបាល EFSB 2.0 ធ្វើការវិនិច្ឆ័យករណីនានាសម្រាប់ទីតាំងថាមពលដែលស្ថិតនៅក្រោមកម្រិតកំណត់ទីតាំង LCEIF របស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង។ ការវិនិច្ឆ័យជាថ្មីពីសំណាក់ក្រុមប្រឹក្សាភិបាល នឹងអនុវត្តតាមលក្ខខណ្ឌតម្រូវរបស់នាយកដ្ឋាន DOER សម្រាប់ការប្រគល់ពាក្យសុំលិខិតអនុញ្ញាតរួមថ្នាក់មូលដ្ឋានទៅកាន់អាជ្ញាធរចេញលិខិតអនុញ្ញាតថ្នាក់ក្រុង។ ក្រោមការវិនិច្ឆ័យសាជាថ្មី ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងអាចនឹងពឹងផ្អែកលើពាក្យសុំលិខិតអនុញ្ញាតថ្នាក់មូលដ្ឋានរួមដែលបានដាក់ជូនពីមុន ហើយមិនតម្រូវឱ្យម្ចាស់សំណើរៀបចំ និងដាក់សំណើបន្ថែមនោះទេ។ ដើម្បីធានាមានរួមបញ្ចូលព័ត៌មានគ្រប់គ្រាន់នៅក្នុងពាក្យសុំលិខិតអនុញ្ញាតរួមថ្នាក់មូលដ្ឋាន ក្រុមប្រឹក្សាភិបាល EFSB នឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយនាយកដ្ឋាន DOER។

E. *តម្រូវការបច្ចេកវិទ្យាព័ត៌មាន*

ពាក្យសុំដែលគ្របដណ្តប់លក្ខខណ្ឌតម្រូវខាងលើទាំងអស់ ទំនងជាមានលក្ខណៈលម្អិតខ្លាំង។ ពាក្យសុំដែលមានស្រាប់មានប្រវែងរាប់រយទំព័ររួចហើយ ដោយមានឯកសារភ្ជាប់គាំទ្ររាប់សិប។

ខ្លឹមសារនៃឯកសារតម្កល់មួយចំនួននឹងត្រូវការផែនទីមានពណ៌ច្បាស់ល្អ រូបភាព ក្រាហ្វ ទិន្នន័យជំនួយ និងឯកសារជាសំឡេងឬរូបភាពវីដេអូជាដើម ។ល។ ដោយមើលឃើញពីទំហំសក្ដានុពលនៃឯកសារតម្កល់នេះ និងការកើនឡើង.[18]ដូច្នេះចាំបាច់ត្រូវឱ្យប្រព័ន្ធឯកសារតម្កល់មានភាពអំណោយផលដល់ការបញ្ជូន ការចូលប្រើប្រាស់ និងការប្រើប្រាស់តាមប្រព័ន្ធអេឡិចត្រូនិកប្រកបដោយប្រសិទ្ធភាព និងគួរឱ្យទុកចិត្តបានពីសំណាក់ក្រុមប្រឹក្សាភិបាល ទីភ្នាក់ងារអនុញ្ញាត និងភាគីពាក់ព័ន្ធផ្សេងទៀត។[19] នាយកដ្ឋានកំពុងធ្វើបច្ចុប្បន្នភាពប្រព័ន្ធឯកសារអេឡិចត្រូនិកដែលមានស្រាប់របស់ខ្លួនក្នុងពេលឆាប់ៗ នេះ ប៉ុន្តែប្រហែលជានៅមិនមានមុខងារចាំបាច់ទាំងអស់ដើម្បីបំពេញតម្រូវការរបស់ក្រុមប្រឹក្សាភិបាល EFSB **2.0** នៅឡើយទេ។ មុខងារពិសេសនៃការដាក់ឯកសារដ៏មានសក្ដានុពលមួយចំនួនដែលអាចបំពេញតម្រូវការឯកសារអេឡិចត្រូនិករបស់ក្រុមប្រឹក្សាភិបាល EFSB **2.0** ឱ្យបានល្អប្រសើរ ត្រូវបានពិពណ៌នាខាងក្រោម។

បន្ទប់ឯកសាររបស់នាយកដ្ឋាន DPU (https://eeaonline.eea.state.ma.us/DPU/Fileroom/dockets/bynumber) គឺជាមជ្ឈមណ្ឌលផ្ទុកមូលដ្ឋានទិន្នន័យសាធារណៈ និងបណ្ណសារសម្រាប់កំណត់ត្រារបស់ក្រុមប្រឹក្សាភិបាល EFSB និងនាយកដ្ឋាន DPU នៃគម្រោងពីមុននិងបច្ចុប្បន្នដែលបានរៀបចំនៅក្នុងសំណុំឯកសារសំណុំរឿង។ សំណុំឯកសារទាំងនេះអាចស្វែងរកតាមលេខ វិស័យ កាលបរិច្ឆេទដាក់ឯកសារ និងលំដាប់កាលប្បវត្តិពីថ្មីទៅចាស់បំផុត (ប្រសិនបើដាក់ក្នុងរយៈពេល **20** ខែមុន)។ បន្ទប់ឯកសារដែលបានកែលម្អកំពុងស្ថិតក្នុងការអភិវឌ្ឍដើម្បីជំនួសប្រព័ន្ធបន្ទប់ឯកសារបច្ចុប្បន្ន និងបានបង្ហាញខ្លួននៅក្នុងខែមីនា ឆ្នាំ **2025**។ សំខាន់បំផុត ប្រព័ន្ធថ្មីអាចស្វែងរកបានតាមរយៈពាក្យគន្លឹះ និងអាចផ្ទុកទំហំឯកសារនីមួយៗបានធំជាងមុន (ឥឡូវនេះផ្ទុករហូតដល់ទំហំ **300** មេកាបៃ)។ ទោះជាយ៉ាងណាក៏ដោយ បន្ទប់ឯកសារថ្មីនៅតែពឹងផ្អែកលើបុគ្គលិករដ្ឋបាលរបស់ទីភ្នាក់ងារដើម្បីអាប់ឡូដរាល់ឯកសារបញ្ជូនដោយដៃនៅក្នុងបណ្ដុំឯកសារ និងបញ្ចូលព័ត៌មានសម្រាប់ចន្លោះបំពេញព័ត៌មានអត្តសញ្ញាណផ្សេងៗនៅក្នុងមូលដ្ឋានទិន្នន័យ។

យើងបានសង្កេតឃើញទីភ្នាក់ងាររដ្ឋជាច្រើននៅក្នុងរដ្ឋម៉ាសាឈូសិត និងនៅកន្លែងផ្សេងទៀតដែលពឹងផ្អែកលើអ្នកដាក់ពាក្យសុំ និងភាគីពាក់ព័ន្ធផ្សេងទៀតក្នុងការបង្ហោះឯកសារដោយផ្ទាល់ទៅក្នុងវិបផតថលបន្ទប់ឯកសារអេឡិចត្រូនិកប្រហាក់ប្រហែលគ្នានេះ។ ការអនុវត្តបែបនេះអាចកាត់បន្ថយការទាមទារលើពេលវេលារបស់បុគ្គលិកក្រុមប្រឹក្សាភិបាល EFSB ដែលនៅពេលនេះបានចំណាយពេលច្រើនលើការបង្ហោះឯកសារនេះដោយដៃ។ យ៉ាងហោចណាស់ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងចង់កែប្រែប្រព័ន្ធឯកសារបច្ចុប្បន្ន ដើម្បីឱ្យមតិសាធារណៈជាច្រើននៅក្នុងបណ្ដុំឯកសាររបស់ក្រុមប្រឹក្សាភិបាល EFSB ត្រូវបានដាក់ជូនដោយផ្ទាល់ទៅកាន់បន្ទប់ឯកសារ ហើយតម្រូវឱ្យមានកិច្ចខិតខំប្រឹងប្រែងផ្នែករដ្ឋបាលតិចតួចបំផុត។ បុគ្គលិកក្រុមប្រឹក្សាភិបាល EFSB ក៏ចាប់អារម្មណ៍ចង់ពិចារណាទៅលើការផ្លាស់ប្ដូរបន្ថែម ឬក៏អាចទៅលើប្រព័ន្ធថ្មីទាំងមូល ដើម្បីសម្រេចបាននូវមុខងារ និងប្រសិទ្ធភាពកាន់តែប្រសើរឡើង។

តាមទស្សនៈរបស់ភ្នាក់ងាររដ្ឋនិងមូលដ្ឋានផ្សេងទៀតដែលជាធម្មតានឹងទទួលបានពាក្យសុំលិខិតអនុញ្ញាត និងប្រើប្រាស់ព័ត៌មាននោះដើម្បីបញ្ចូលប្រព័ន្ធព័ត៌មានផ្សេងទៀតដែលពួកគេប្រើ អាចនឹងមានការព្រួយបារម្ភជាពិសេសអំពីការផ្លាស់ប្ដូរទៅកាន់ក្រុមប្រឹក្សាភិបាល EFSB **2.0** ដែលជាអង្គភាពទទួល និងដំណើរការពាក្យសុំ។ ដំណើរការពាក្យសុំថ្មីរបស់ក្រុមប្រឹក្សាភិបាល EFSB នឹងត្រូវដោះស្រាយបញ្ហាតម្រូវការរបស់ទីភ្នាក់ងារទាំងនេះ ដើម្បីធានាថាពួកគេអាចបន្តអនុវត្តមុខងារសំខាន់ៗដូចជា ការត្រួតពិនិត្យការអនុលោមភាព ដែលនៅតែជាទំនួលខុសត្រូវរបស់ទីភ្នាក់ងារ

---

[18] សូមមើលរបាយការណ៍ CEISP ស្ដីពីការកើនឡើងដែលបានរំពឹងទុកនៃហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីដែលត្រូវការការអនុញ្ញាត ដើម្បីបំពេញតាមគោលដៅអាកាសធាតុតាមការចង់បានរបស់រដ្ឋ។ https://www.mass.gov/doc/recommendations-to-governor-maura-healey-on-clean-energy-infrastructure-siting-and-permitting-reform/download.

[19] ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ **2024** តម្រូវឱ្យក្រុមប្រឹក្សាភិបាល EFSB បង្កើតនិងថែរក្សាផ្ទាំងគ្រប់គ្រង ដែលនឹងផ្ដល់ទីតាំងមួយសម្រាប់ភាគីពាក់ព័ន្ធក្នុងការស្វែងរកព័ត៌មាន នៅលើពាក្យសុំ។ ច្បាប់លក្ខន្តិកឆ្នាំ **2024** ជំពូក **239** ផ្នែក **8** ផ្ទាំងគ្រប់គ្រងដំបូងអាចមាននៅទីនេះ៖ https://www.mass.gov/info-details/efsb-permitting-dashboard.

ដែលមានយុត្តាធិកា នៅពេលចេញលិខិតអនុញ្ញាតរួមរបស់ក្រុមប្រឹក្សាភិបាល EFSB។ លើសពីនេះ ទៀត ទីភ្នាក់ងារផ្សេងទៀតបានបង្ហាញពីចំណាប់អារម្មណ៍ក្នុងការជូនដំណឹងភ្លាមៗ ដើម្បីជូនដំណឹង ដល់ពួកគេនៅពេលដែលព័ត៌មានពាក់ព័ន្ធត្រូវបានដាក់ជូនក្រុមប្រឹក្សាភិបាល EFSB **2.0** ហើយ ទីភ្នាក់ងារតម្រូវឱ្យពិនិត្យឡើងវិញ ដើម្បីផ្តល់សេចក្តីថ្លែងបញ្ជាក់អំពីលក្ខខណ្ឌអនុញ្ញាតដែលបាន ណែនាំ។ ក៏មានតម្រូវការសម្រាប់ក្រុមប្រឹក្សាភិបាល EFSB **2.0** និងទីភ្នាក់ងារផ្សេងទៀតក្នុងការ វាយតម្លៃថាតើពាក្យសុំដែលបានដាក់ស្នើមានលក្ខណៈពេញលេញ និងមានដំណើរការសម្របសម្រួល ទាន់ពេលវេលា មានប្រសិទ្ធភាព និងមានប្រសិទ្ធផលក្នុងការដោះស្រាយបញ្ហានោះ។

F. *ការកំណត់ភាពពេញលេញនៃពាក្យសុំ*

ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ **2024** តម្រូវឱ្យក្រុមប្រឹក្សាភិបាល EFSB សម្រេចថាតើ ពាក្យសុំមានភាពពេញលេញហើយឬនៅ ប៉ុន្តែមិនបានចែងថាតើភាព "ពេញលេញ" នោះមាន ន័យដូចម្តេចទេ ដូច្នេះហើយទើប ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងត្រូវតែធ្វើការកំណត់និយមន័យ។ ដោយមើលឃើញពីសារៈសំខាន់នៃការប្តេជ្ញាចិត្តនេះចំពោះពេលវេលានៃការត្រួតពិនិត្យនិងអភិវឌ្ឍគម្រោង ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងចាំបាច់ត្រូវផ្តល់ភាពច្បាស់លាស់ និងជៀសវាងស្តង់ដាដែលមិនច្បាស់ លាស់ ឬមានភាពអត្តនោម័តិខ្លាំងពេក ដែលបង្ហាញចេតនាកំណែទម្រង់លិខិតបទដ្ឋាននៃដំណើរ ការកំណត់ទីតាំងនិងការអនុញ្ញាតនេះ។ ក្រុមប្រឹក្សាកំណត់ទីតាំងផ្តល់និយមន័យនៃពាក្យសុំ "ពេញ លេញ" ដូចខាងក្រោម៖

> "ពាក្យសុំដែលអនុលោមគួរឱ្យកត់សម្គាល់និងជាសារវន្តទៅតាមលក្ខខណ្ឌតម្រូវព័ត៌មាន ទាំងអស់ដែលបានបង្កើតឡើងនៅក្នុងលក្ខន្តិក លិខិតបទដ្ឋាន និងគោលនយោបាយ ដែលអាចអនុវត្តបានក្នុងការពិនិត្យឡើងវិញនូវពាក្យសុំរបស់ CEIF ដោយក្រុមប្រឹក្សា ភិបាលកំណត់ទីតាំង។ ការសម្រេចនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយមន្ត្រី វិនិច្ឆ័យសេចក្តី ហើយមិនត្រូវប្តឹងតវ៉ាឡើយ។"

និយមន័យដែលបានស្នើទទួលស្គាល់ថា មានហានិភ័យច្រើនប្រឈមនឹងភាពយឺតយ៉ាវផ្នែកនីតិវិធី ប្រសិនបើស្តង់ដានៃភាពពេញលេញត្រូវបានព្យាករណ៍លើ "ភាពល្អឥតខ្ចោះ" ពោលគឺ មិនត្រូវការការស៊ើបអង្កេតបន្ថែម ឬការស្វែងរកការពិតបន្ថែមក្នុងអំឡុងពេលដំណាក់កាលនៃនីតិវិធី បង្ហាញភស្តុតាងជាបន្តបន្ទាប់។ ជាទូទៅ ពាក្យសុំត្រូវតែរួមបញ្ចូល៖ (i) មានការពិពណ៌នាត្រឹមត្រូវ និងពេញលេញអំពីទីកន្លែង ទីតាំង និងតំបន់ជុំវិញ។ (ii) មានភស្តុតាងបញ្ជាក់ពីការបំពេញទាំងស្រុង តាមលក្ខខណ្ឌតម្រូវមុនដាក់ពាក្យសុំ។ (iii) មានរាល់លក្ខខណ្ឌតម្រូវពាក្យសុំទាំងអស់ រួមទាំងព័ត៌មាន គ្រប់គ្រាន់ដើម្បីឱ្យទីភ្នាក់ងាររដ្ឋនិងមូលដ្ឋានផ្តល់សេចក្តីថ្លែងការណ៍អំពីលក្ខខណ្ឌលិខិតអនុញ្ញាតដែល បានណែនាំ។ និង (iv) ភស្តុតាងគ្រប់គ្រាន់ដើម្បីឱ្យក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបង្កើតលទ្ធផល ស្រាវជ្រាវដែលបានកំណត់។ ដោយមើលឃើញពីតម្រូវការសម្រាប់ការវិនិច្ឆ័យក្នុងការអនុវត្តស្តង់ដា នេះ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងសង្កត់ធ្ងន់លើការពិចារណាជាក់លាក់មួយចំនួនដែលជាផ្នែកមួយ នៃការសម្រេចចិត្តនេះ៖

- ពាក្យស្នើសុំត្រូវតែកំណត់ លិខិតអនុញ្ញាត ការអនុញ្ញាត និងការអនុម័តថ្នាក់មូលដ្ឋាន ថ្នាក់ តំបន់ និងថ្នាក់រដ្ឋដែលនឹងចាំបាច់ក្នុងការសាងសង់ និងដំណើរការទីតាំងគ្រឿងសូានដែលបាន ស្នើឡើង ប្រសិនបើក្រុមប្រឹក្សាភិបាលកំណត់ទីតាំងមិនចេញលិខិតអនុញ្ញាតរួមទេ ។[20] រាល់សំណួរទាក់ទងនឹងភាពអាចអនុវត្តទៅលើលក្ខខណ្ឌតម្រូវលិខិតអនុញ្ញាត និងព័ត៌មាន ដែលបានរំពឹងទុកដោយទីភ្នាក់ងារទាំងនោះ ត្រូវតែដោះស្រាយដោយម្ចាស់សំណើរជា មួយទីភ្នាក់ងារអនុញ្ញាត មុនពេលដាក់ពាក្យសុំ។

---

20 ក្រុមប្រឹក្សាកំណត់ទីតាំងក៏នឹងត្រូវបង្កើតលក្ខខណ្ឌតម្រូវការដែលនឹងអនុវត្ត ប្រសិនបើអ្នកដាក់ ពាក្យសុំមិនបានកំណត់លិខិតអនុញ្ញាតដែលត្រូវការចាំបាច់នៅក្នុងពាក្យសុំរបស់ខ្លួន។ ទីភ្នាក់ ងារណាមួយដែលជាធម្មតាមានយុត្តាធិការទាក់ទងនឹងលិខិតអនុញ្ញាតដែលមិនបានរួមបញ្ចូល នេះ គួរតែអាចធ្វើអន្តរាគមន៍ដោយមិនគិតពីពេលដែលរកឃើញការមិនបានរួមបញ្ចូលនោះទេ។ បទប្បញ្ញត្តិដំណោះស្រាយបញ្ហាផ្សេងទៀតក៏អាចចាំបាច់ផងដែរ។

- ពាក្យស្នើសុំត្រូវតែបង្ហាញពីភាពពិតខំប្រឹងប្រែងផ្តល់ព័ត៌មានដែលជាចម្មតាត្រូវបានផ្តល់ឱ្យទៅទីភ្នាក់ងារថ្នាក់មូលដ្ឋាន ថ្នាក់តំបន់ និងថ្នាក់រដ្ឋនីមួយៗសម្រាប់លិខិតអនុញ្ញាត ការអនុញ្ញាត និងការអនុម័ត។ ព័ត៌មានស្ទួន ឬលក្ខខណ្ឌតម្រូវដែលផ្ទុយគ្នានៅក្នុងកម្មវិធីលិខិតអនុញ្ញាតដែលបានរួមបញ្ចូលទៅក្នុងពាក្យសុំ ត្រូវកំណត់យ៉ាងច្បាស់, បានផ្ទៀងផ្ទាត់យោង (តាមការចាំបាច់), និងដំណោះស្រាយដែលបានស្នើឡើងទៅលើលក្ខខណ្ឌតម្រូវដែលផ្ទុយគ្នាដែលបានផ្តល់ជូននោះ ដោយមានការបកស្រាយពន្យល់គ្រប់គ្រាន់។[21]

- ពាក្យសុំត្រូវតែរួមបញ្ចូលឯកសារគាំទ្រ ឯកសារការងារ គំរូ ការសិក្សាស្រាវជ្រាវ និងសិទ្ធិអំណាចដែលបានលើកឡើង ត្រូវតែទទួលបានក្នុងកម្រិតលម្អិត និងជាទម្រង់បែបបទដែលបានកំណត់ដោយលិខិតបទដ្ឋាននិងការណែនាំរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង។ និង

- អ្នកដាក់ពាក្យត្រូវតែបំពេញ និងបញ្ចូក់ "តារាងត្រួតពិនិត្យភាពពេញលេញ" ដែលបានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាល EFSB ។

## IV. សំណើសុំមតិយោបល់

បុគ្គលិកស្នើសុំមតិយោបល់លើខ្លឹមសារណាមួយនៅក្នុងពង្រាងសំណើគម្រោង ក៏ដូចជាការឆ្លើយតបទៅនឹងសំណួរខាងក្រោម។

1. បុគ្គលិកស្នើឱ្យប្រើគំរូរួមសម្រាប់ពាក្យសុំដែលបានដាក់តាំងពីឆ្នាំ **2026** ហើយពិចារណាថាតើត្រូវផ្លាស់ប្តូរទៅកាន់គំរូដែលបង្កើតឡើងក្នុងគោលបំណងជាក់លាក់ដែរឬអត់។ តើក្រុមប្រឹក្សាភិបាល EFSB គួរតែមានគម្រោងប្រើប្រាស់គំរូរួមក្នុងរយៈពេលវែង ឬផ្លាស់ប្តូរទៅកាន់ការបង្កើតគំរូដែលបង្កើតឡើងក្នុងគោលបំណងជាក់លាក់ដែរឬទេ? ហេតុអ្វី?

2. ប្រសិនបើក្រុមប្រឹក្សាភិបាលកំណត់ទីតាំងចាំបាច់ត្រូវបង្កើតពាក្យសុំរួមមួយបន្ទាប់ពីឆ្នាំ **2026** តាមរយៈគំរូដែលបង្កើតឡើងក្នុងគោលបំណងជាក់លាក់សម្រាប់ទីតាំងគ្រឹះស្ថានប្រភេទផ្សេងទៀត សូមផ្តល់យោបល់លើអត្ថប្រយោជន៍នៃលក្ខខណ្ឌតម្រូវពាក្យសុំរបស់ ទីតាំងបញ្ជូនចរន្តខ្នាតធំនិង ទីតាំងរោងចក្រផលិតថាមពលកកើតឡើងវិញ ដែលដែលបានចេញនាពេលថ្មីៗនេះនៅក្នុងពង្រាងលិខិតបទដ្ឋានដែលធ្វើឡើងដោយការិយាល័យថាមពលអគ្គិសនីទីក្រុងញូវយ៉ក។

3. ដោយសារតែការវិនិច្ឆ័យដែលអាចមានទៅលើទីតាំង SCEIF ពីសំណាក់ក្រុមប្រឹក្សាភិបាល EFSB ក្រោមមធ្យោបាយលិខិតបទដ្ឋានជាក់លាក់ និងការអភិវឌ្ឍរបស់នាយកដ្ឋាន DOER ទៅលើស្តង់ដាកំណត់ទីតាំងនិងពាក្យសុំសម្រាប់ទីតាំងគ្រឹះស្ថានទាំងនោះ តើអ្វីជាមធ្យោបាយដ៏ល្អបំផុតក្នុងការកែតម្រូវតួនាទីក្រុមប្រឹក្សាភិបាល EFSB និងនាយកដ្ឋាន DOER នីមួយៗឱ្យសមស្របតាមសម្រាប់ទីតាំងគ្រឹះស្ថានទាំងនេះ?

4. ប្រសិនបើក្រុមប្រឹក្សាភិបាល EFSB ចាំបាច់ត្រូវបង្កើតប្រព័ន្ធឯកសារអេឡិចត្រូនិកថ្មី ឬបានកែសម្រួលគួរឱ្យកត់សម្គាល់សម្រាប់ក្រុមប្រឹក្សាភិបាល EFSB **2.0** សូមពណ៌នាអំពីលក្ខណៈពិសេស និងមុខងារដែលសំខាន់បំផុត។

5. ដោយសារការកើនឡើងដែលបានរំពឹងទុកនៅក្នុងសំណុំរឿងជាច្រើនសម្រាប់ក្រុមប្រឹក្សាភិបាល EFSB **2.0** ខ្លឹមសារប្រធានបទទូលំទូលាយនៃសំណុំរឿងរបស់ក្រុមប្រឹក្សាភិបាល EFSB ការចូលរួម

---

21 ក្នុងការដោះស្រាយភាពផ្ទុយគ្នារវាងកម្មវិធីលិខិតអនុញ្ញាត ក្រុមប្រឹក្សាភិបាល EFSB អាចបង្កើតការណែនាំដែលបង្គាប់ឱ្យអ្នកដាក់ពាក្យសុំប្រើប្រាស់លក្ខខណ្ឌតម្រូវដែលកំណត់តឹងរឹងបំផុត លើកលែងតែវាមានភាពផ្ទុយគ្នាទៅនឹងគោលបំណងច្បាប់លក្ខន្តិក ឬលិខិតបទដ្ឋានផ្សេងទៀត ហើយត្រូវបានចងក្រងជាឯកសារនៅក្នុងឯកសារដាក់ពាក្យសុំ។

ជាសាធារណៈកាន់តែច្រើន និងតួនាទីវិនិច្ឆ័យសាជាថ្មីរបស់ក្រុមប្រឹក្សាភិបាល EFSB ថ្មី តើសមាសធាតុអ្វីខ្លះដែលចាំបាច់នៅក្នុងវេទិកាកម្មវិធីឯកសារអេឡិចត្រូនិកដែល បានកែប្រែ?

6. តើពាក្យសុំគួរបញ្ចាក់ស្តង់ដាជាតួលេខជាក់លាក់ និងវិធីសាស្ត្រវិភាគសម្រាប់ធ្វើការវិភាគសំឡេង ការវិភាគហ្វ្រេកង់អេឡិចត្រូម៉ាញ៉េទិច ការវិភាគផលប៉ះពាល់ទេសភាពទីតាំង និងការសិក្សាចាំបាច់ផ្សេងទៀតដែរឬទេ?

7. តាមរយៈតួនាទីវិនិច្ឆ័យសាឡើងវិញរបស់ក្រុមប្រឹក្សាភិបាល EFSB **2.0** អនុលោមតាមផ្នែក **69**W តើក្រុមប្រឹក្សាកំណត់ទីតាំងអាចធានាបានដូចម្តេចថា (បន្ទាប់ពីបានដាក់ជូនក្រុមប្រឹក្សា ក្រុងជាលើកដំបូងសម្រាប់គោលបំណងទទួលបានលិខិតអនុញ្ញាតថ្នាក់មូលដ្ឋានរបស់ពួកគេ) កំណត់ត្រាដែលបានដាក់ជូនក្រុមប្រឹក្សាភិបាលបំពេញតាមលក្ខខណ្ឌតម្រូវភស្តុតាងនិងនីតិវិធី?

8. តើកង្វល់ឬអនុសាសន៍អ្វីទៀតដែលអ្នកមានដើម្បីណែនាំការអភិវឌ្ឍពាក្យសុំរបស់ក្រុមប្រឹក្សាភិបាល EFSB?

## V. <u>ឧបសម្ព័ន្ធ</u>

### A. *<u>ឧបសម្ព័ន្ធ "A"៖ ទិដ្ឋភាពទូទៅនៃលិខិតអនុញ្ញាតការកំណត់ទីតាំងសំខាន់ៗសម្រាប់ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត</u>*

**ដូចបានពន្យល់ខាងដើម ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 បង្កើតដំណើរការផ្តល់លិខិតអនុញ្ញាតរួមថ្មី ដែលក្រុមប្រឹក្សាភិបាល** EFSB **នឹងផ្តល់រាល់ការអនុម័តចាំបាច់ថ្នាក់មូលដ្ឋាន ថ្នាក់តំបន់ និងថ្នាក់រដ្ឋជូនដល់ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតធំ (**"LCIEF"**) ហើយក្នុងស្ថានភាពមួយចំនួន លិខិតអនុញ្ញាតរួមថ្នាក់រដ្ឋ និង/លិខិតអនុញ្ញាតរួមថ្នាក់មូលដ្ឋានសម្រាប់ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតតូច") (**"LCEIF"**) ។ ដើម្បីវាយតម្លៃថាតើអាចនឹងមានរួមបញ្ចូលលិខិតអនុញ្ញាតថ្នាក់រដ្ឋ ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋានផ្សេងៗអ្វីខ្លះនៅក្នុងលិខិតអនុញ្ញាតរួមរបស់ក្រុមប្រឹក្សាភិបាល** EFSB **បុគ្គលិកបានពិនិត្យមើលករណីវិញ្ញាបនបត្រក្រុមប្រឹក្សាភិបាល** EFSB **និងឯកសារថ្មីៗ។ ការអនុញ្ញាតទាំងនោះត្រូវបានសង្ខេបនៅក្នុងតារាងទី 1 ខាងក្រោម។ តារាងទី 1 មិនរួមបញ្ចូលបញ្ជីទាំងស្រុងនៃរាល់លិខិតអនុញ្ញាតដែលអាចមានទាំងអស់នោះទេ ប៉ុន្តែគូសបញ្ជាក់ពីលិខិតអនុញ្ញាតថ្នាក់រដ្ឋ ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋាន ដែលបុគ្គលិករំពឹងថាក្រុមប្រឹក្សាភិបាល** EFSB **អាចរួមបញ្ចូលជាមួយលិខិតអនុញ្ញាតរួមរបស់ខ្លួន។**

**តារាង 1. លិខិតអនុញ្ញាតថ្នាក់រដ្ឋ ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋានគឺតម្រូវឱ្យមានជាទូទៅសម្រាប់ការកំណត់ទីតាំងថាមពល។**

| ទីភ្នាក់ងារ | លិខិតអនុញ្ញាត | លក្ខន្តិកៈ និង/ឬលិខិតបទដ្ឋានពាក់ព័ន្ធ | ភាពពាក់ព័ន្ធទៅនឹងការកំណត់ទីតាំង CEIF |
|---|---|---|---|
| **លិខិតអនុញ្ញាតថ្នាក់រដ្ឋ** | | | |
| ក្រុមប្រឹក្សាធនធានបុរាណវិទ្យាក្រោមទឹកនៃរដ្ឋម៉ាសាឈូសិត | លិខិតអនុញ្ញាតឱ្យសិក្សាស្វែងយល់ ការជីកកកាយ ឬការប្រើប្រាស់ពិសេសសម្រាប់ធនធានបុរាណវិទ្យាក្រោមទឹក។ | ច្បាប់ទូទៅ ជំពូក 6 ផ្នែក 179-180, ក្រម CMR មាត្រា 312 ផ្នែក 2.00 | តម្រូវឱ្យមានក្នុងករណីដែលម្ចាស់សំណើស្វែងរកការសិក្សាអង្កេតធនធានបុរាណវត្ថុវិទ្យាក្រោមទឹកដែលមានសក្តានុពលក្នុងអំឡុងពេលធ្វើផែនការគម្រោង និងក្នុងករណីដែលទីតាំងគ្រឹះស្ថានអាចនឹងប៉ះពាល់ដល់ទីតាំងដែលគេស្គាល់។ |
| នាយកដ្ឋានអភិរក្សនិងការកម្សាន្តរដ្ឋម៉ាសាឈូសិត (MassDCR) | លិខិតអនុញ្ញាតឱ្យចូលសាងសង់ ប្រើប្រាស់ផ្លូវ និងធ្វើពាណិជ្ជកម្មរយៈពេលខ្លី | ក្រម CMR មាត្រា 302 ផ្នែក 12.00៖ | តម្រូវឱ្យមានក្នុងករណីដែលទីតាំងគ្រឹះស្ថាននៅក្នុងបរិវេណ ប៉ះពាល់ ឬពាក់ព័ន្ធនឹងការសាងសង់លើអចលនទ្រព្យរបស់នាយកដ្ឋាន DCR ឬនៅក្នុងសិទ្ធិប្រើប្រាស់ផ្លូវរបស់នាយកដ្ឋាន DCR (ឧទាហរណ៍ ខ្សែបញ្ជូនចរន្តដែលលាតសន្ធឹង ឬស្របផ្លូវហាយវ៉េយ៍ ការខួងតាមទិសដៅនៅក្រោមផ្លូវហាយវ៉េយ៍)។ |

| ទីភ្នាក់ងារ | លិខិតអនុញ្ញាត | លក្ខន្តិ និង/ឬលិខិត បទដ្ឋានពាក់ព័ន្ធ | ភាពពាក់ព័ន្ធទៅនឹងការកំណត់ទីតាំង CEIF |
|---|---|---|---|
| នាយកដ្ឋានការពារបរិស្ថានរដ្ឋម៉ាសាជូសេត (MassDEP) | វិញ្ញាបនបត្របញ្ជាក់គុណភាពទឹក ផ្នែក 401 នៃច្បាប់ | ច្បាប់ទូទៅ ជំពូក 21 ផ្នែក 26-53, ក្រម CMR មាត្រា 314 ផ្នែក 9.00, ច្បាប់ទឹកស្អាត (ក្រម USC មាត្រា 33 ផ្នែក 1251 និងផ្នែកបន្តបន្ទាប់), ក្រម CFR មាត្រា 40 ផ្នែក 121 | តម្រូវឱ្យមានក្នុងករណីដែលទីតាំងគ្រឹះស្ថានជាប់ពាក់ព័ន្ធនឹងការបញ្ចេញចោលនូវសារធាតុដែលបានបូម ការបូម ឬសកម្មភាពបោះចោលសារធាតុដែលបានបូមនៅក្នុងដែនទឹកសហរដ្ឋអាមេរិកក្នុងរដ្ឋម៉ាសាឈូសិត ដែលតម្រូវឱ្យមានអាជ្ញាប័ណ្ណ ឬលិខិតពីសហព័ន្ធ ហើយដែលស្ថិតក្រោមការបញ្ជាក់គុណភាពទឹករបស់រដ្ឋ អនុលោមតាមក្រម USC មាត្រា 33 ផ្នែក 1251 ។ ធានាថាសកម្មភាពបញ្ចេញចោលដែលបានអនុញ្ញាតដោយសហព័ន្ធ ត្រូវអនុលោមតាមស្តង់ដាគុណភាពទឹករបស់រដ្ឋ។ ផ្នែក 401 វិញ្ញាបនបត្រគុណភាពទឹកក៏តម្រូវឱ្យមានផងដែរសម្រាប់ការបញ្ចេញចោលផ្សេងទៀត (ឧទាហរណ៍ លិខិតអនុញ្ញាត NPDES និងអាជ្ញាប័ណ្ណវារីអគ្គិសនីដែលចេញដោយ FERC) ។ |
| MassDEP | ជំពូកទី 91 អាជ្ញាប័ណ្ណផ្លូវទឹក។ | ច្បាប់ទូទៅ ជំពូក 91, ក្រម CMR មាត្រា 310 ផ្នែក 9.00 | តម្រូវឱ្យមានក្នុងករណីដែលទីតាំងគ្រឹះស្ថានជាប់ពាក់ព័ន្ធនឹងការសាងសង់ ការចាក់បំពេញ ឬការបូមខ្សាច់នៅតំបន់ទឹកជោរ ស្រះទឹកធំៗ និងទន្លេនិងស្ទឹងដែលគ្មានទឹកជំនោរ។ |
| MassDEP | ការអនុម័តផែនការបញ្ចេញផ្សែងក្នុងអាកាសលម្អិតចុងក្រោយ និងលិខិតអនុញ្ញាតឱ្យបញ្ចេញផ្សែងក្នុងអាកាសផ្សេងទៀត | ច្បាប់ទូទៅ ជំពូក 111 ផ្នែក 142A-142M, (សម្រាប់ការបំភាយឧស្ម័នផ្ទះកញ្ចក់) ច្បាប់ទូទៅ ជំពូក 21N, ច្បាប់ទូទៅ ជំពូក 30 ផ្នែក 62-62L ក្រម CMR មាត្រា 310 ផ្នែក 7.00 ច្បាប់ខ្យល់អាកាសបរិសុទ្ធរបស់សហព័ន្ធ (ក្រម USC មាត្រា 42 | តម្រូវឱ្យមានក្នុងករណីដែលទីតាំងគ្រឹះស្ថានជាប់ពាក់ព័ន្ធនឹងការបំភាយឧស្ម័នក្នុងបរិយាកាសនៅពេលប្រតិបត្តិការ។ លិខិតអនុញ្ញាតជាក់លាក់ ពឹងផ្អែកលើប្រភេទនិងកម្រិតនៃការបំភាយឧស្ម័នដែលរំពឹងទុក និងស្ថានភាពខ្យល់អាកាសតាមមូលដ្ឋាន។ |

| ទីភ្នាក់ងារ | លិខិតអនុញ្ញាត | លក្ខន្តិ និង/ឬលិខិតបទដ្ឋានពាក់ព័ន្ធ | ភាពពាក់ព័ន្ធទៅនឹងការកំណត់ទីតាំង CEIF |
|---|---|---|---|
| | | ផ្នែក 7401 និងផ្នែកបន្តបន្ទាប់), ផែនការអនុវត្តរបស់រដ្ឋ (ក្រម CFR មាត្រា 40 ផ្នែកទី 51) | |
| MassDEP | លិខិតអនុញ្ញាតឱ្យបញ្ចេញទឹកក្រោមដី (ទូទៅ និងដាច់ដោយឡែក) | ច្បាប់ទូទៅ ជំពូក 21 ផ្នែក 27 & 43, លិខិតអនុញ្ញាតឱ្យបញ្ចេញទឹកក្រោមដី៖ ក្រម CMR មាត្រា 314 ផ្នែក 5.00, លិខិតអនុញ្ញាតឱ្យប្រើប្រាស់ទឹកដែលបានធ្វើប្រព្រឹត្តកម្ម៖ ក្រម CMR មាត្រា 314 ផ្នែក 20.00, នីតិវិធីអនុញ្ញាត៖ ក្រម CMR មាត្រា 314 ផ្នែក 2.00៖ | តម្រូវឱ្យមានក្នុងករណីទីតាំងគ្រឹះស្ថានជាប់ពាក់ព័ន្ធនឹងការបញ្ចេញទឹកខ្វក់ដែលបានប្រើប្រាស់ខាងផ្នែកអនាម័យ ឬផ្នែកឧស្សាហកម្មទៅលើដី (ឧទាហរណ៍ សកម្មភាពបង្ហូរទឹកសំខាន់ៗ) |
| MassDEP | ការដាក់ជំនួសសេចក្តីបង្គាប់កំណត់លក្ខខណ្ឌ | ច្បាប់ទូទៅ ជំពូក 131 ផ្នែក 40 (ច្បាប់ការពារតំបន់ដីសើម), ក្រម CMR មាត្រា 310 ផ្នែក 10.00 | តម្រូវឱ្យមានក្នុងករណីម្ចាស់សំណើប្តឹងតវ៉ាលើការសម្រេចចិត្តលើតំបន់ដីសើមតាមមូលដ្ឋានទៅកាន់ការិយាល័យប្រចាំតំបន់របស់នាយកដ្ឋាន MassDEP។ |
| MassDEP | លិខិតអនុញ្ញាតឱ្យប្រើប្រាស់ជាបន្តក្រោយការបិទបញ្ចប់ការដ្ឋាន | ច្បាប់ទូទៅ ជំពូក 111 ផ្នែក 150A និងក្រម CMR មាត្រា 310 ផ្នែក 19.000 | តម្រូវឱ្យមានសម្រាប់ការប្រើប្រាស់កន្លែងចាក់សំរាមក្រោយពេលបិទបញ្ចប់ការដ្ឋាន ដើម្បីធានាថាគម្រោងនឹងមិនបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានដល់សុខភាពសាធារណៈ សុវត្ថិភាព ឬបរិស្ថាន។ នឹងមិនធ្វើឱ្យខូចដល់សុចរិតភាពនៃគម្របការពារកន្លែងចាក់សំរាម ការទប់ស្កាត់ ការគ្រប់គ្រង ឬប្រព័ន្ធត្រួតពិនិត្យឡើយ។ ផ្តល់ការថែទាំប្រព័ន្ធលូបង្ហូរទឹកជំនន់ទឹកភ្លៀងរបស់គម្របការពារកន្លែងចាក់សំរាម។ |

| ទីភ្នាក់ងារ | លិខិតអនុញ្ញាត | លក្ខន្តិ និង/ឬលិខិតបទដ្ឋានពាក់ព័ន្ធ | ភាពពាក់ព័ន្ធទៅនឹងការកំណត់ទីតាំង CEIF |
|---|---|---|---|
| នាយកដ្ឋានដឹកជញ្ជូនរដ្ឋម៉ាសាជូសេត | លិខិតអនុញ្ញាតឱ្យប្រើប្រាស់សម្រាប់យានយន្ត និងមិនសម្រាប់យានយន្ត | ច្បាប់ទូទៅ ជំពូក 81 ផ្នែក 21, ក្រម CMR មាត្រា 700 ផ្នែក 13.00 | តម្រូវឱ្យមានក្នុងករណីដែលទីតាំងគ្រឹះស្ថាននៅក្នុងបរិវេណ ប៉ះពាល់ ឬពាក់ព័ន្ធនឹងការសាងសង់នៅក្នុងសិទ្ធិប្រើប្រាស់ផ្លូវរបស់នាយកដ្ឋាន DCR (ឧទាហរណ៍ ខ្សែបញ្ជូនចរន្តដែលលាតសន្ធឹង ឬស្របផ្លូវហាយវ៉េយ៍ ការខួងតាមទិសដៅនៅក្រោមផ្លូវហាយវ៉េយ៍)។ |
| នាយកដ្ឋាននេសាទនិងល្បែងកម្សាន្ត (DFG) | ច្បាប់ស្ដីពីអំបូរសត្វជិតផុតពូជរដ្ឋម៉ាសាឈូសិត (“MESA”) ការត្រួតពិនិត្យគម្រោងលិខិតសម្រេច លិខិតអនុញ្ញាតសម្រាប់ការអភិរក្សនិងគ្រប់គ្រង | ច្បាប់ទូទៅ ជំពូក 131A, ក្រម CMR មាត្រា 321 ផ្នែក 10.00 | តម្រូវឱ្យមានក្នុងករណីទីតាំងគ្រឹះស្ថានជាប់ពាក់ព័ន្ធនឹងកន្លែងទីជម្រកពពួកសត្វដែលរដ្ឋបានចុះបញ្ជី។ ការត្រួតពិនិត្យគម្រោង MESA អាចកើតឡើងដោយមានការសម្របសម្រួលជាមួយនឹងការអនុញ្ញាតសម្រាប់តំបន់ដីសើម ឬដាច់ដោយឡែក អាស្រ័យលើគម្រោងនោះ។[22] ក៏ត្រូវអនុវត្តផងដែរនូវសមាសធាតុទីជម្រកអំបូរសត្វព្រៃកម្រនៅតំបន់ដីសើមនៅក្នុងច្បាប់ការពារតំបន់ដីសើម។ |
| ភ្នាក់ងារពន្លត់អគ្គិភ័យរដ្ឋម៉ាសាឈូសិត នាយកដ្ឋានសេវាពន្លត់អគ្គីភ័យ (DFS) | លិខិតអនុញ្ញាតសាងសង់ធុងស្តុកខ្ពស់ផុតពីដី និងលិខិតអនុញ្ញាតការប្រើប្រាស់ | ច្បាប់ទូទៅ ជំពូក 148 ផ្នែក 37, ក្រម CMR មាត្រា 502 ផ្នែក 5.00 | តម្រូវឱ្យមានក្នុងករណីទីតាំងគ្រឹះស្ថានមានអាងស្តុកខ្ពស់ផុតពីលើដីដែលមានចំណុះជាង 10,000 ហ្គាឡុង និងទុកវត្ថុរាវផ្សេងទៀតក្រៅពីទឹក |
| លិខិតអនុញ្ញាតកម្រិតតំបន់ | | | |
| គណៈកម្មាធិការតំបន់ Cape Cod | ការអភិវឌ្ឍការអនុម័តផលប៉ះពាល់ក្នុងតំបន់ | ច្បាប់គណៈកម្មាធិការតំបន់ Cape Cod (ច្បាប់លក្ខន្តិកឆ្នាំ 1989 ជំពូក 716, វិសោធនច្បាប់លក្ខន្តិកឆ្នាំ 1990 ជំពូក 2, វិសោធនកម្មច្បាប់លក្ខន្តិកឆ្នាំ 2014 ជំពូក 259) | តម្រូវឱ្យមានក្នុងករណីទីតាំងគ្រឹះស្ថានមានលើសពីកម្រិតគោលនៃផលប៉ះពាល់ក្នុងតំបន់ដែលកំណត់ដោយគណៈកម្មាធិការតំបន់ Cape Cod។ ធានាថាការអភិវឌ្ឍដែលប៉ះពាល់ដល់តំបន់មូលដ្ឋានជាច្រើនគឺស្របជាមួយនឹងឯកសារផែន |

[22] មុខងារច្បាប់ MESA របស់ផ្នែក DFW អាចជាកម្មវត្ថុនៃការដកចេញពីលិខិតអនុញ្ញាតរួម ដោយផ្អែកលើបទប្បញ្ញត្តិប្រគល់សិទ្ធិ គ្រប់គ្រងដល់សហព័ន្ធ។ មើលច្បាប់លក្ខន្តិកឆ្នាំ 2024 ជំពូក 239 ផ្នែក 52

| ទីភ្នាក់ងារ | លិខិតអនុញ្ញាត | លក្ខន្តិកៈ និង/ឬលិខិតបទដ្ឋានពាក់ព័ន្ធ | ភាពពាក់ព័ន្ធទៅនឹងការកំណត់ទីតាំង CEIF |
|---|---|---|---|
| | | | ការសំខាន់ៗ រួមទាំង "ផែនការគោលនយោបាយថ្នាក់តំបន់" របស់គណៈកម្មការតំបន់ Cape Cod ផងដែរ។ |
| គណៈកម្មការចំការទំពាំងបាយជូរតំបន់កោះ Martha (“MVC”) | ការអភិវឌ្ឍការអនុម័តផលប៉ះពាល់ក្នុងតំបន់ | ច្បាប់គណៈកម្មការចំការទំពាំងបាយជូរតំបន់កោះ Martha (**ច្បាប់លក្ខន្តិកឆ្នាំ 1977 ជំពូក 831)** | ផ្តល់សិទ្ធិឱ្យ MVC ពិនិត្យឡើងវិញនូវការអភិវឌ្ឍដែលមានទំហំធំ ឬមានផលប៉ះពាល់យ៉ាងសំខាន់លើតំបន់ជុំវិញរបស់ពួកគេ ដែលពួកគេអាចនឹងប៉ះពាល់ដល់ទីក្រុងច្រើនលើសពីមួយ។ គម្រោងនេះត្រូវបានដាក់ឈ្មោះថា ការអភិវឌ្ឍដែលមានផលប៉ះពាល់ក្នុងតំបន់ (DRI)។ នៅពេលដែលបានចាត់ថ្នាក់ជាផ្លូវការថាជា DRI គម្រោងត្រូវតែបានអនុម័តដោយគណៈកម្មាធិការ MVC មុនពេលក្រុមប្រឹក្សាក្រុងអាចចេញលិខិតអនុញ្ញាតដែលចាំបាច់ ឬចាត់វិធានការណាមួយ។ |
| លិខិតអនុញ្ញាតរបស់អាជ្ញាធរធនធានទឹករដ្ឋម៉ាសាជូសេត | ផ្នែក **8(**m) | ច្បាប់លក្ខន្តិកឆ្នាំ **1984** ជំពូក **372** ផ្នែក **8(**m) | តម្រូវឱ្យមានក្នុងករណីដែលទីតាំងគ្រឹះស្ថានមានពាក់ព័ន្ធនឹងការកសាងការសាងសង់ ការជីកកកាយ ឬឆ្លងកាត់ទីតាំងដែលមានសិទ្ធិឆ្លងកាត់ ឬផលប្រយោជន៍អចលនទ្រព្យផ្សេងទៀតដែលគ្រប់គ្រងដោយ MWRA ។ |
| លិខិតការអនុញ្ញាតកម្រិតមូលដ្ឋាន | | | |

| ទីភ្នាក់ងារ | លិខិតអនុញ្ញាត | លក្ខន្តិ និង/ឬលិខិតបទដ្ឋានពាក់ព័ន្ធ | ភាពពាក់ព័ន្ធទៅនឹងការកំណត់ទីតាំង CEIF |
|---|---|---|---|
| គណៈកម្មការអភិរក្សថ្នាក់មូលដ្ឋាន | សេចក្តីបង្គាប់កំណត់លក្ខខណ្ឌនៃតំបន់ដីសើម | ច្បាប់ទូទៅ ជំពូក 131 ផ្នែក 40 (ច្បាប់ការពារតំបន់ដីសើម), ក្រម CMR មាត្រា 310 ផ្នែក 10.00, បទប្បញ្ញត្តិការពារតំបន់ដីសើមក្នុងមូលដ្ឋាន | តម្រូវឱ្យមានក្នុងករណីដែលទីតាំងគ្រឹះស្ថានអាចប៉ះពាល់ដល់តំបន់ដីសើមដែលត្រូវបានការពារ និងតំបន់ទ្រនាប់របស់ពួកគេ។ |
| នាយកដ្ឋានវិស្វកម្ម/អគារ/អធិការកិច្ចថ្នាក់មូលដ្ឋាន | ការអនុម័តរបស់អធិការកិច្ចសំណង់អគារ (ឧ. លិខិតអនុញ្ញាតសាងសង់អគារ លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតសាងសង់គ្រឹះអគារ វិញ្ញាបនបត្របញ្ជាក់ការចូលកាន់កាប់) | ច្បាប់ទូទៅ ជំពូក 143 ផ្នែក 3-3A, ក្រមអគាររដ្ឋម៉ាសាឈូសិត (ក្រម CMR មាត្រា 780), ក្រមសុវត្ថិភាពអគ្គិភ័យលម្អិតរបស់រដ្ឋម៉ាសាឈូសិត (ក្រម CMR មាត្រា 527 ផ្នែក 1.00).[23] | តម្រូវឱ្យធានាថាទីតាំងគ្រឹះស្ថាននោះអនុលោមតាមក្រមច្បាប់អគាររបស់រដ្ឋម៉ាសាឈូសិត (ដែលរួមបញ្ចូលស្តង់ដាសុវត្ថិភាពអគ្គិភ័យ រចនាសម្ព័ន្ធ អគ្គិសនី និងស្តង់ដាសុវត្ថិភាពផ្សេងទៀត) និងការប្រែប្រួលតាមមូលដ្ឋានណាមួយ (ឧទាហរណ៍ ដីកាកំណត់មណ្ឌលប្រវត្តិសាស្ត្រ) ចំពោះអគារ ឬរចនាសម្ព័ន្ធណាមួយដែលមិនមែនជាកម្មសិទ្ធិរបស់រដ្ឋទាំងស្រុង ឬផ្នែកខ្លះឡើយ។ សម្រាប់ប្រព័ន្ធផ្ទុកថាមពលថ្ម អ្នកត្រួតពិនិត្យអគារថ្នាក់មូលដ្ឋានត្រូវធានានូវអនុលោមភាពតាមក្រមសុវត្ថិភាពអគ្គីភ័យលម្អិតរបស់រដ្ឋម៉ាសាឈូសិតដែលជាធាតុផ្សំមួយនៃការចេញលិខិតអនុញ្ញាតសាងសង់។ |
| ក្រុមប្រឹក្សារៀបចំផែនការ/កំណត់តំបន់ (ការអនុម័តចុងក្រោយពីក្រុមប្រឹក្សាភិបាលជ្រើសរើសថ្នាក់មូលដ្ឋាន ឬក្រុមប្រឹក្សាក្រុង) | ការអនុម័តផែនការទីតាំង | ច្បាប់ទូទៅ ជំពូក 40A ផ្នែក 9, ច្បាប់ទូទៅ ជំពូក 41 ផ្នែក 81A-81J ច្បាប់ទូទៅ ជំពូក 40A ផ្នែក 3 | តម្រូវឱ្យមានជាសក្តានុពលដើម្បីធានាថាទីតាំងគ្រឹះស្ថានមួយអនុលោមតាមការកំណត់តំបន់ថ្នាក់មូលដ្ឋាន លិខិតបទដ្ឋានប្រើប្រាស់ដីធ្លី និងគោលបំណងផែនការសហគមន៍។ អ្នកអភិវឌ្ឍគម្រោងទំនងជានឹងស្នើសុំការអនុគ្រោះ ពីការពិនិត្យមើលផែនការទីតាំងថ្នាក់មូលដ្ឋាន |

[23] ក្រម CMR មាត្រា 527 ផ្នែក 1.00 រួមបញ្ចូលលក្ខខណ្ឌតម្រូវជាពិសេសសម្រាប់ប្រព័ន្ធថ្មថាមពលអចល័ត (រួមទាំងប្រព័ន្ធថ្មលីចូម-អ៊ីយ៉ុង)។ ក្រម CMR មាត្រា 527 ផ្នែក 1.00 រួមបញ្ចូលដោយស្តង់ដាយោង និងក្រមច្បាប់នានាជាច្រើនពីសមាគមការពារអគ្គីភ័យជាតិ (NFPA) រួមទាំង NFPA 855 ដែលបង្កើតស្តង់ដាសុវត្ថិភាពជាតិនិងអន្តរជាតិសម្រាប់ការដំឡើងត្រឹមត្រូវនូវប្រព័ន្ធផ្ទុកថាមពលអចល័ត។

| ទីភ្នាក់ងារ | លិខិតអនុញ្ញាត | លក្ខន្តិកៈ និង/ឬលិខិតបទដ្ឋានពាក់ព័ន្ធ | ភាពពាក់ព័ន្ធទៅនឹងការកំណត់ទីតាំង CEIF |
|---|---|---|---|
| | | | ដោយស្នើសុំឱ្យក្រុមប្រឹក្សាភិបាល EFSB ចេញការលើកលែងការកំណត់តំបន់ជាក់លាក់និងចម្រុះរួម។ |
| ក្រុមប្រឹក្សារៀបចំផែនការ/កំណត់តំបន់ (ការអនុម័តចុងក្រោយពីក្រុមប្រឹក្សាភិបាលជ្រើសរើសថ្នាក់មូលដ្ឋាន ឬក្រុមប្រឹក្សាក្រុង) | លិខិតអនុញ្ញាតពិសេស | ច្បាប់ទូទៅ ជំពូក 40A ផ្នែក 9 (លើកលែងតែទីក្រុង Boston ដែលត្រូវបានគ្រប់គ្រងដោយច្បាប់លក្ខន្តិកឆ្នាំ 1956 ជំពូក 665), បទប្បញ្ញត្តិមូលដ្ឋាន ច្បាប់ទូទៅ ជំពូក 40A ផ្នែក 3 | តម្រូវឱ្យមានជាសក្តានុពលក្នុងករណីដែលទីតាំងគ្រឹះស្ថានមួយពឹងផ្អែកលើការកំណត់តំបន់ថ្នាក់មូលដ្ឋានដោយគ្រាន់តែជា "ការប្រើប្រាស់" ដែលអាចអនុញ្ញាតបាន ស្ថិតក្រោមលិខិតអនុញ្ញាតពិសេស។ អ្នកអភិវឌ្ឍគម្រោងទំនងជានឹងដោះស្រាយបញ្ហាការកំណត់តំបន់និងការប្រើប្រាស់ ដោយស្នើសុំការលើកលែងឱ្យក្រុមប្រឹក្សាភិបាល EFSB ចេញការលើកលែងការកំណត់តំបន់ចម្រុះរួមនិងជាក់លាក់ ។ |
| ក្រុមប្រឹក្សាភិបាលកំណត់តំបន់ថ្នាក់មូលដ្ឋាននៅក្នុងបណ្តឹងតវ៉ា | អញ្ញត្រកម្ម និងបណ្តឹងតវ៉ាការកំណត់តំបន់ | ច្បាប់ទូទៅ ជំពូក 40A ផ្នែក 9-17 (លើកលែងតែទីក្រុង Boston ដែលត្រូវបានគ្រប់គ្រងដោយច្បាប់លក្ខន្តិកឆ្នាំ 1956 ជំពូក 665) ច្បាប់ទូទៅ ជំពូក 40A ផ្នែក 3 | តម្រូវឱ្យមានជាសក្តានុពលក្នុងករណីដែលទីតាំងគ្រឹះស្ថានមួយតម្រូវឱ្យមានការអនុគ្រោះ ពីស្តង់ដារអភិវឌ្ឍន៍ដែលរួមបញ្ចូលនៅក្នុងបទប្បញ្ញត្តិកំណត់តំបន់ថ្នាក់មូលដ្ឋាន។ អ្នកអភិវឌ្ឍន៍គម្រោងទំនងជានឹងដោះស្រាយបញ្ហាការអនុគ្រោះលើការតំបន់តំបន់ដោយស្នើសុំក្រុមប្រឹក្សាភិបាល EFSB ឱ្យចេញនូវការលើកលែងការដាក់តំបន់ជាក់លាក់និងចម្រុះរួម។ |
| នាយកដ្ឋានសាធារណៈការ ឬវិស្វកម្មថ្នាក់មូលដ្ឋាន | លិខិតអនុញ្ញាតឱ្យមានការបង្ហូរ/ការតភ្ជាប់ប្រព័ន្ធលូ | ច្បាប់ទូទៅ ជំពូក 83 ផ្នែក 1 | តម្រូវឱ្យមានក្នុងករណីដែលទីតាំងគ្រឹះស្ថានមួយអាចនឹងតភ្ជាប់ និង/ឬបង្ហូរទឹកទៅកាន់ប្រព័ន្ធលូដែលគ្រប់គ្រងក្នុងមូលដ្ឋាន (ឧ. ការបង្ហូរទឹកសំណង់ រចនាសម្ព័ន្ធដែលកាន់កាប់ថ្មី) ។ |
| នាយកដ្ឋានសាធារណៈការ ឬវិស្វកម្មថ្នាក់មូលដ្ឋាន | លិខិតអនុញ្ញាឱ្យបើកផ្លូវ/ជីកកាយ/ជីករណ្តៅ | លិខិតអនុញ្ញាតឱ្យបើកផ្លូវសម្រាប់សេវាសាធារណៈ៖ ច្បាប់ទូទៅ ជំពូក 166 ផ្នែក 25, សុវត្ថិភាពការជីកកកាយ និងការជីករណ្តៅ៖ | តម្រូវឱ្យមានក្នុងករណីដែលការសាងសង់ទីតាំងគ្រឹះស្ថានមានជាប់ទាក់ទងនឹងការជីកកកាយផ្លូវសាធារណៈ (ឧ. ផ្លូវថ្នល់ ចិញ្ចើមផ្លូវ)។ ធានាការសាងសង់គម្រោង៖ 1) ត្រូវបានសម្របសម្រួលជាមួយសេវាសុវត្ថិ |

| ទីភ្នាក់ងារ | លិខិតអនុញ្ញាត | លក្ខន្តិ និង/ឬលិខិតបទដ្ឋានពាក់ព័ន្ធ | ភាពពាក់ព័ន្ធទៅនឹងការកំណត់ទីតាំង CEIF |
| --- | --- | --- | --- |
| | | ច្បាប់ទូទៅ ជំពូក 82A ("ច្បាប់ Jackie"), ក្រម CMR មាត្រា 520 ផ្នែក 14.00 | ភាព និងចរាចរណ៍ផ្លូវគោក និង 2) អនុលោមតាមលក្ខខណ្ឌតម្រូវសុវត្ថិភាព។ |
| ក្រុមប្រឹក្សាជ្រើសរើសថ្នាក់មូលដ្ឋាន ឬក្រុមប្រឹក្សាក្រុង | ការផ្តល់ទីតាំង | ច្បាប់ទូទៅ ជំពូក 166 ផ្នែក 22 | តម្រូវឱ្យមានក្នុងករណីទីតាំងគ្រឹះស្ថានមានទីតាំងស្ថិតនៅជាអចិន្ត្រៃយ៍នៅក្នុងតំបន់ផ្លូវសាធារណៈ។ |
| ឆ្មាំយាមដើមឈើក្នុងមូលដ្ឋាន និង/ឬក្រុមប្រឹក្សារៀបចំផែនការថ្នាក់មូលដ្ឋាន | លិខិតអនុញ្ញាតកាប់ដើមឈើចេញ លិខិតអនុញ្ញាតរុះរើជញ្ជាំងថ្ម | ច្បាប់ទូទៅ ជំពូក 40 ផ្នែក 15C ច្បាប់ទូទៅ ជំពូក 87 | តម្រូវឱ្យមានករណីដែលទីតាំងគ្រឹះស្ថានមួយកាប់ដើមឈើម្លប់សាធារណៈចេញ ដើមឈើនៅតាមដងផ្លូវទេសភាពដែលបានកំណត់ និងរុះរើជញ្ជាំងថ្មមួយចំនួន។ ទំហំដើមឈើសម្រាប់តម្រូវឱ្យមានលិខិតអនុញ្ញាតនេះគឺប្រែប្រួលទៅតាមលិខិតបទដ្ឋានថ្នាក់មូលដ្ឋាន។ មានគោលបំណងការពារលក្ខណៈសោភណភាពនៃផ្លូវដែលមានទេសភាព។ |